# មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0076

## សម្ភាសន៍ជាមួយឈ្មោះ និន នាម ភេទប្រុស អាយុ៥៨ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ «កងចល័តឃុំនិមិត្ត»
## មុខងារបច្ចុប្បន្នៈ «ជំទប់ទី១ឃុំអូរស្រឡៅ»
## ស្រុកកំណើតនៅភូមិគោកក្នុង ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបាត់ដំបង
## សព្វថ្ងៃរស់នៅភូមិអូរស្រឡៅ ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ ឆាយ ឈុនលី
## ០១:១០:០២
## ៣១ទំព័រ

នាម : ៧៥ បែកពី ។

ឈុនលី : ចេញពីភូមិមក?

នាម : ខ្ញុំបែកពីចេញពីភូមិកំណើតរបស់ខ្ញុំ មកធ្វើកងចល័តនៅនិមិត្ត ។

ឈុនលី : និយាយទៅពីដំបូងមក?

នាម : បាទ! ពីដំបូង ។

ឈុនលី : ស្រុកកំណើតពូនៅណា?

នាម : បាទ! ស្រុកកំណើតខ្ញុំនៅស្រុកមង្គលបូរី ឃុំបន្ទាយនាង ភូមិគោកក្នុង ខេត្តបាត់ដំបង ។

ឈុនលី : កាលនឹងខេត្តបាត់ដំបង?

នាម : បាទ! ៧៥ខ្ញុំមកធ្វើចល័តនៅនិមិត្ត ។

ឈុនលី : ធ្វើការអីខ្លះ?

នាម : កងចល័តដូចដឹងស្រាប់ហើយ គេធ្វើស្រែ លើកទំនប់ ជីកប្រឡាយ សម័យយើង ។ ហើយដល់ឆ្នាំ១៩៧៩ ចឹងរត់យួនគេហៅរត់យួន ។

ឈុនលី : អ៊ីចង់សួរ៧៥នឹង ចូលកងចល័តនឹងអត់មានជម្រើសទៅណា?

នាម : ទេ! អានឹងដូចៗដែលគេជម្រើសពីភូមិយើងនឹង គេឲ្យយុវជន យុវនារីនឹង មកនៅនិមិត្តនឹងធ្វើកងចល័ត ។

ឈុនលី : ចឹងកាលនឹងនៅនិមិត្ត?

នាម : បាទ! ដែលកូនដំរីយើង ។

ឈុនលី : និមិត្តនឹងជាស្រុក ឬក៏អីគេ?

នាម ៖ អានឹងភូមិៗនិមិត្ត ។

ឈុនលី ៖ ឃុំអីគេទៅ?

នាម ៖ ឃុំកូប ។

ឈុនលី ៖ កូបតូច កូបធំ?

នាម ៖ កូបធំ ។

ឈុនលី ៖ ចុះកូបតូចនៅណា?

នាម ៖ កូបតូចនៅកើតកូបធំទៀត ។

ឈុនលី ៖ អានឹងឃុំដែរ?

នាម ៖ អឺ! កាលពីមុនមិនដឹងដែរ ខ្ញុំអត់ទាន់មានមកដល់នេះផង ប៉ុនបើភូមិៗនិមិត្ត ឃុំ ។

ឈុនលី ៖ ហើយស្រុកអីគេទៅ?

នាម ៖ ស្រុកអូរជ្រៅ ។

ឈុនលី ៖ ចឹងអ៊ំរស់នៅកងចល័តនឹងរហូតមក តាំងពី៧៥?

នាម ៖ បាទ! តាំងពី៧៥មករហូត ។

ឈុនលី ៖ អត់មានធ្វើការងារអីផ្សេងទៀតទេ?

នាម ៖ ទេ! គ្មានធ្វើស្អី អានឹងយើងគ្រាន់ធ្វើថា ដឹកប្រឡាយ លើកទំនប់ សម័យនឹងដូចដឹងស្រាប់ហើយ ដឹកប្រឡាយ លើកទំនប់ ស្ទូងស្រូវអីចឹង ។

ឈុនលី ៖ ហើយមានបងប្អូនអីមកធ្វើជាមួយ?

នាម ៖ អូ! អានឹងមកគ្រប់ ក្នុងម៉ាខេត្តអឺ! ក្នុងម៉ាស្រុកមង្គលបូរីមកគ្រប់ឃុំ ។

ឈុនលី ៖ ចុះឪពុកម្ដាយអ៊ំអីនៅធ្វើការនឹងដែរ?

នាម ៖ ទេ! ម៉ែឪខ្ញុំ បងប្អូនខ្ញុំនៅផ្ទះ ។

ឈុនលី ៖ នៅមង្គលបូរីនឹង?

នាម ៖ បាទ! នៅភូមិគោកក្ដុល ឃុំបន្ទាយនាងនោះ ដោយឡែកតែខ្ញុំយើងកម្លាំងយុវជន ។

ឈុនលី ៖ ហើយដូចឆ្នាំ៧៦ ៧៧ ៧៨នៅនឹង?

នាម ៖ បាទ! ដល់៧៩យួនចូលមកនឹង យើងរត់ចូលព្រៃហើយ រត់ទៅស្រុកខ្លាចយួនអា-ក ។

ឈុនលី ៖ រត់ទៅណាដំបូង?

នាម ៖ រត់មកនឹង ។

ឈុនលី ៖ ទីតាំងនៅនឹង?

នាម ៖ ទេ! រត់ចូលព្រៃ យើងដល់រត់ចូលព្រៃចឹងហើយ គេរៀបជាកងឈ្លប ។

ឈុនលី ៖ ហើយចឹងគេឲ្យអ៊ំធ្វើកងឈ្លប?

នាម ៖ កងឈ្លបដើម្បីទៅតស៊ូគ្នាវិញ ទៅសមរភូមិ ។

ឈុនលី ៖ កាលនឹងសមរភូមិគេនៅណា?

នាម ៖ នៅនិមិត្តនឹងឯង ហើយយើងមកដល់កូបហើយ យើងរៀបចំឈ្លបហើយ យើងមិនទៅវៃវិញ ទៅវៃនៅនិមិត្ត ។

ឈុនលី ៖ កងឈ្លងនឹងទីតាំងគេនៅណា?

នាម ៖ ទីតាំងគេមិនសូវកំណត់ប៉ុន្មានទេ កងឈ្លប ម៉េចហៅកងឈ្លប សិននៅនេះម៉ាយប់ ដកចេញទៅនោះម៉ាយប់ៗ ម៉េចហៅថាឈ្លប អត់មានទីតាំងកំណត់ ។

ឈុនលី ៖ ចុះពេលមកៗគ្នាច្រើន?

នាម ៖ បាទ! មកគ្នាច្រើនរាប់ពាន រាប់ម៉ឺននាក់ គេនៅបណ្ដោយចែកគ្នាជាក្រុមៗធ្វើសកម្មភាពវៃយួនដែលគេរៀបជាកងឈ្លបម៉ាត់ៗ ជួនកាល៣នាក់ ២នាក់ ឬម៉ាក្រុម ឬ៥នាក់ ទៅឆ្មក់ទៅវៃម៉ាក្ដុងម៉ាក្ដាំងអីចឹងទៅ យើងរត់មកវិញ ហើយផ្លាស់ទីតាំងយើងចេញទៀត ។

ឈុនលី ៖ អានឹងខ្ទង់ឆ្នាំណា ៧៩?

នាម ៖ បាទ! ៧៩រហូតមកដល់យើងផ្ដាច់ខ្លួន ៩៦ ៩០ប៉ុន្មានពូអ្នកជិតខាង ខ្ញុំភ្លេចហើយ ។

ឈុនលី ៖ ផ្ដាច់ខ្លួន?

នាម ៖ ហ៊ើ! ៩៦ ។

ឈុនលី ៖ ចុះ៩៣?

នាម ៖ ៩៣នឹង គេខាងអី!

ឈុនលី ៖ អ៊ុនតាក់?

នាម ៖ អ៊ុនតាក់ បាទ! កាលអ៊ុនតាក់ ខ្មែរក្រហមនឹងគេម៉េចគេថាធ្វើអី....មិនចូល ។

ឈុនលី ៖ ពហិកា?

នាម ៖ ហ្នឹងហើយ ។

ឈុនលី ៖ មិនចូលរួមបោះឆ្នោត?

នាម ៖ បាទ! ហ្នឹងចឹងគឺខ្មែរក្រហមនឹងនៅបន្តវៃតទៅទៀតមិនចឹង រហូតដល់ឆ្នាំ៩៦នេះបានយើងសមាហរណកម្មនេះចូលរួមកម្លាំងគ្នាជាមួយរាជរដ្ឋាភិបាល ។

ឈុនលី ៖ ចុះអ៊ំកាលអ៊ំនៅ៧៥នឹង ដូចកង មេកងអីចឹងអ៊ំស្គាល់ឈ្មោះគេដែរ?

នាម ៖ យូរហើយ មេកងគេនឹងវាជួនកាលគេដកបាត់ទៅ ជួនកាលគេយកពីខាងកើតៗនឹងមកដាក់មក ។

ឈុនលី ៖ ស្គាល់ឈ្មោះ?

នាម ៖ បាទ! វាភ្លេចហើយ យូរណាស់ហើយ ។

ឈុនលី ៖ ចុះដល់ពេលយើងវត់មកនឹង អ្នកណាគេអ្នកដឹកនាំវត់មក?

នាម ៖ បាទ! អ្នកណាទាំងយើងទាំងគេ មកទាំងអស់គ្នា ពុថាយួនហើយខ្ញុំមក ។

ឈុនលី ៖ ចឹងដូចមេកងអីកាលពីមុនមកដល់នេះដែរ?

នាម ៖ មកដល់នេះគឺបែកគ្នាអស់ គេបំបែកគ្នាទៅក៏ចេញទៅតាមមុខសញ្ញារៀងខ្លួនទៅ ។

ឈុនលី ៖ ចុះដូចឈ្លបនឹងកាលនឹងមានគ្នាច្រើន?

នាម ៖ បាទ! ឈ្លបនឹងគ្នាច្រើនដែរ វារៀបទៅជាកងឈ្លបនឹងម៉ាក្រុមៗ១០នាក់ៗ ។

ឈុនលី ៖ មានច្រើនក្រុម?

នាម ៖ បាទ! វាមានច្រើនក្រុមរហូតដល់វរៈនោះ ។ អានឹងដែលយើងវត់មកចូលព្រៃរៀបកម្លាំងកងឈ្លបដើម្បីតស៊ូ វាអត់ទាន់មានសំលៀកបំពាក់ខោអាវស៊ីម៉ាលីទេ ខោអាវយើងមកពីកងចល័តរបៀបម៉េច គេហៅថាខោអាវសជ្រលក់សំបកឈើឲ្យរៀងពណ៌ខ្មៅៗតិចនឹង ដូនកាលទៅខោអាវសចេះធម្មតា អានឹងកងឈ្លប ។ ដល់ពេលខាងរាជរដ្ឋាភិបាលគាត់ខាងនេះកម្ពុជាប្រជាធិបតេយ្យ គាត់ទាក់ទងបានខោបានអាវមកបានមានខោអាវស៊ីម៉ាលីយើងនឹងណា ។

ឈុនលី ៖ ពេលណាបានមានខោអាវ?

នាម ៖ ឆ្នាំប៉ុន្មានទេ ពូអ្នកជិតខាងចាំទេអាយើងពាក់ខោអាវស៊ីម៉ាលី ។

រិទ្ធ ៖ បាទ! ៧៩ ។

នាម ៖ ៧៩ អត់ទាន់មានទេ ។

រិទ្ធ ៖ អឺ!ចូលចុង៧៩ហើយ យើងវត់៧៩ដើមវាអត់មាន ដល់យើងមកដល់នឹងហើយបានចាប់ផ្តើមមានហើយ ។

នាម ៖ បាទ! មានខោអាវនឹង ខោអាវស៊ីម៉ាលីពាក់ចុង៧៩ អាច៨០ ។

ឈុនលី ៖ ចឹងដូចមកនឹងដំបូងចឹង គេហៅតំបន់អីគេ?

នាម ៖ អានេះតំបន់ភ្នំម៉ាឡៃ ។

ឈុនលី ៖ កាលនឹងគេអត់ទាន់មានឈ្មោះជាស្រុកអី?

នាម ៖ អត់ទេ ព្រៃ កន្លែងផ្ទះខ្ញុំនេះមើលថ្ងៃអត់ឃើញទេ ។

ឈុនលី ៖ អីគេ?

រិទ្ធ ៖ រនាមដូចសមពីដើម ។

នាម ៖ ព្រៃៗរនាម ។

រិទ្ធ ៖ បាទ! ប៉ុនឈ្មោះហៅនាមដូនសំ ។

នាម ៖ យាយសំៗ ។

ឈុនលី ៖ យាយសំម៉េច ពូដឹងអីដឹង?

នាម ៖ ប្រវត្តិយាយសំនេះ ខ្ញុំកើតមកក្លាមទៅដឹង អានេះរបៀបថាម្ចាស់ទឹកម្ចាស់ដីម្ចាស់ព្រៃគេម្ចាស់ភ្នំគេដែលគេថែរក្សា ខ្ញុំកើតមិនទាន់ទេ ។ ដូចយាយអីនៅពេជ្រនិល ។

ឈុនលី ៖ យាយម៉ៅ?

នាម ៖ អឺ! យើងអត់ដឹង ឃើញយាយម៉ៅយ៉ាងម៉េចទេ ប៉ុន្តែតែឈ្មោះមិនចឹង អានឹងវាមានយាយម៉ៅ យាយយ៉ាត យាយសំម៉ង់ប៉ែកខាងនេះ ។

ឈុនលី ៖ ចឹងពេលអ៊ំមកដំបូង សុទ្ធតែព្រៃអានឹងចាញ់ទេ?

នាម ៖ បាទ! រឿងចាញ់ហើយវាអ្នកខ្វះគ្នាទ្រាំទ្រអាផាប់ ចាញ់សំបើមណាស់ អ្នកចាញ់ក៏ចាញ់ទៅពេទ្យទៅ មានមន្ទីរពេទ្យ ។

ឈុនលី ៖ កាលនឹងមានមន្ទីរពេទ្យមានអីទៀត?

នាម ៖ មាន ។

ឈុនលី ៖ ចឹងសរុបទៅគេបង្កើតជារបៀបម៉េចវិញ បានមានពេទ្យមានឈ្នួប?

នាម ៖ ចឹងគេបង្កើតជារបៀបថា បើគេរៀបឈ្នួប១០ គឺមានពេទ្យមួយ ។

ឈុនលី ៖ ពេទ្យម្នាក់?

នាម ៖ បាទ!

ឈុនលី ៖ ចឹងបានន័យថានៅក្នុងក្រុម១០នាក់នឹង មានពេទ្យមួយនៅនឹង?

នាម ៖ បាទ! អានឹងសម្រាប់ឧទាហរណ៍ថាយើងគ្រូន ប៉ុនមានទីតាំងគេមួយគេមានមន្ទីរពេទ្យ អានឹងគេហៅមន្ទីរពេទ្យចល័តទៅតាមសមរភូមិ ។

ឈុនលី ៖ ចឹងគេមានអគ្គភាពមានអី ។ ចឹងមានសាលារៀនអត់?

នាម ៖ ទេ! សម័យនឹងដូចវាមិនទាន់មានកូនក្មេង កាលនោះដូចខ្ញុំចឹង ខ្ញុំនៅកំលោះពូខាងនោះក៏នៅកំលោះ មីងខាងនោះក៏នៅក្រមុំ នាងខាងនេះក៏នៅក្រមុំៗកំលោះទាំងអស់ អត់មានពុកម៉ែណាកូនរញ៉េករញ៉ៃចអីទេ ។

ឈុនលី ៖ ចុះអ្នកមានគ្រួសារ?

នាម ៖ អត់ទាន់មានកាលនោះ បាទ! មានដូចពូគាត់និយាយចឹង វាមានភាគតិចនឹងវាច្រើនតែមេគេធំៗគេយកដាក់ម៉ាកន្លែងអាឧទាហរណ៍ថាណាបឹងបេងនោះ ។

ឈុនលី ៖ អានឹងម៉េច កន្លែងអីគេ?

នាម ៈ អានឹងសម្រាប់ប្រពន្ធយោធា អានឹងគេដាក់នោះម៉ាកន្លែងនឹងទៅ ។

ឈុនលី ៈ ឈ្លបនឹងខុស ពីយោធា ខុសពីទ័ព ដូចអ៊ំនិយាយថាទ័ពទៅច្បាំងនៅនោះ?

នាម ៈ អាទៅច្បាំងនឹងវាខុសតែពីឯកសណ្ឋានតិចនឹង ពាក្យថាយោធានេះវាពេញលក្ខណៈរបស់គេ ហើយបើនិយាយឈ្លបនោះកាំភ្លើងអឹមស៊ីនឹងគេឲ្យ២០គ្រាប់វាអត់បង់ បើយើងកាន់សេកាសេនឹងគេឲ្យ១០គ្រាប់តែប៉ុននឹង គេឲ្យគ្រាប់យើងម៉ាសាងនឹងវាមាន១០គ្រាប់តែប៉ុននឹង ។ ហើយអ៊ឹមស៊ីនឹងគេឲ្យយើង២០គ្រាប់ ហើយអត់មានអាបង់ញាត់ពីក្រោមអីទេ ។ យើងបច្ចេកទេសបាញ់ម៉េចកើត បាញ់ទៅ ចឹងហើយបេះដាក់ម្តងម៉ាគ្រាប់ទៅ ។

ឈុនលី ៈ ចឹងដល់ពេលអ៊ំមកដំបូងមិនត្រូវរៀនហាត់បាញ់សិន?

នាម ៈ ដល់ពេលនឹងដូចបេះចឹងក្លួយ មិនបាច់ហាត់ទេ ឡើងទៅជុលមុខគ្នាចឹង បើខ្ញុំមិនបាញ់នាងនាងបាញ់ខ្ញុំស្លាប់មិនចឹង ។ ចឹងបេះហើយ ត្រូវតែបេះ ពេលនឹងមិនបាច់ហាត់ពិបាកអីទេ ។

ឈុនលី ៈ ចុះអ៊ំដឹងហើយដូចថាអ្នកដឹកនាំឈ្លបទាំងអស់ គាត់អ្នកណាគេ ឈ្មោះអី?

នាម ៈ អានឹងពីមុនវាយើងអត់ទាន់មានមេចង្កោមធំទេ ដល់ពេលយើងរៀបហៅថាយោធា អានឹងវាមានសម្ភារៈទាំងអស់ ។

ឈុនលី ៈ ពេលណាបានគេរៀបចឹង?

នាម ៈ ដឹងឆ្នាំប៉ុន្មានបេះ ៨០ ។

ឈុនលី ៈ គេរៀបមានកង?

នាម ៈ បាទ! មានកងតូច កងធំ វាមានតាំងពីក្រុមពួកអីចឹងទៅ ពួកក្រុម កងតូច កងធំ វរសេនាតូច វរសេនាធំ ។

ឈុនលី ៈ ចុះបើអ្នកក្តាប់រួមទាំងអស់ម៉ង?

នាម ៈ បាទ! ក្តាប់រួមទាំងអស់ គ្មានអ្នកណា មានភាពយើងនឹង ។

ឈុនលី ៈ សុខ ភាព?

នាម ៈ ហ្អឹងហើយៗតាផុន ហ្អឹងម៉ាផ្នែកម៉ាកងពល គេនិយាយម៉ាកងពល ។

ឈុនលី ៈ ប៉ុន្តែម៉ាកងពលនឹង ក្តោបទាំងអ្នកដូចថាឈ្លបអីទាំងអស់?

នាម ៈ បាទ! ប្រជាជនប្រជាអីទាំងអស់ ។

ឈុនលី ៈ បើគិតទៅគាត់មិនមែនជាគណៈតំបន់ចឹង ព្រោះគាត់ខាងទ័ព?

នាម ៈ មិនមែនទេ បាទ! ខាងទ័ព ។

រិទ្ធ ៈ អត់មាននិយាយរឿងតំបន់អីទៀតទេ

ឈុនលី ៈ ចុះគណៈតំបន់ខាងណា?

នាម ៖ អស់តំបន់ហើយ ។

ឈុនលី ៖ អត់មានទេ?

នាម ៖ អត់មានតំបន់ទេ ។

រិទ្ធ ៖ តំបន់តែ៣ឆ្នាំទេ តែចូល៧៩មកគ្មានលែងហៅតំបន់ហៅអីទៀតហើយ ។

ឈុនលី ៖ ចុះកាលជំនាន់៣ឆ្នាំ នៅនេះគេហៅតំបន់អីគេ?

នាម ៖ នៅនេះគេហៅកាលខ្ញុំនៅនេះគេហៅតំបន់៣ នៅនិមិត្ត ។ ដល់រត់ចូលព្រៃអត់មានតំបន់ មានព្រៃទៅវិញ មិនដឹងថាម៉េចវិញ ។

ឈុនលី ៖ ចុះអ៊ំថាឈ្មោះ ផុន?

នាម ៖ បាទ! ផុន តាភាព តាផុន ។

ឈុនលី ៖ តាផុននឹងត្រកូលអីគេ?

នាម ៖ តាផុនមួយទៀត តាមនឹងគាត់ស្លាប់ហើយ ។

ឈុនលី ៖ អត់ដឹងត្រកូលគាត់ទេ?

នាម ៖ បាទ!

ឈុនលី ៖ គាត់ធ្វើអីគេ?

នាម ៖ អានឹងវរសេនាធំ ។

ឈុនលី ៖ ក្រោមតាភាព?

នាម ៖ ក្រោម តាភាព គាត់ធំណាស់ ។

ឈុនលី ៖ បើគិតទៅម៉ាកងពលមានប៉ុន្មានវរសេនាធំ?

នាម ៖ ហ៎! វាកងពលវា៣វរសេនាធំ ។

រិទ្ធ ៖ វាមានពលតូច ពលធំ ពលតូចវាមាន៣វរសេនាធំ បើពលធំវាមាន៣កងពលតូចចេះ ។ ប៉ុននៅម៉ាខ្សែនេះវាមានតែមួយវរសេនាធំទេ ។

ឈុនលី ៖ មួយវរសេនាធំនឹង គ្រប់គ្រងដោយតាផុននឹង?

នាម ៖ នៅតាភាព ។

រិទ្ធ ៖ ហ្នឹងហើយភាព ផុននឹង ផុន១២នាក់ ប៉ុនផុនមួយស្លាប់ហើយ មានភាព មានផុនគេហៅផុនតូច ផុនធំ ។

ឈុនលី ៖ ចុះផុនតូច អ្នកណាគេស្លាប់?

រិទ្ធ ៖ ផុនធំស្លាប់ ។

ឈុនលី ៖ ចុះផុនតូចឥឡូវគាត់នៅណា?

នាម ៖ ផុនតូចគាត់នៅខាងភូមិភាគ ។

រិទ្ធ ៖ ឧត្តមសេនីយ៍ ។

នាម ៖ នៅសល់តែ២នាក់មួយស្លាប់ ផុនធំនឹងគាត់ស្លាប់ហើយ នៅផុនតូច ប៉ុនគាត់នៅផ្នែកខាងភូមិភាគ ។ ដូចតាភាពនឹងដឹងគាត់ទៅខាងអី ខាងដោះស្រាយជម្លោះតាមព្រំដែន ។

ឈុនលី ៖ ចុះតាផុនទាំង២នឹង គាត់មុខងារធ្វើអីខ្លះ?

នាម ៖ អានឹងបើនិយាយរួមទៅ ឧទាហរណ៍ថាខ្ញុំ៣នាក់ អានេះហៅថាស្នងការបញ្ជាការបញ្ជាទ័ព ស្នងការផ្នែកនយោបាយ ទៅខាងកំពូលនោះផ្នែកសេរីសេដ្ឋកិច្ចអីចឹងទៅ អានឹងគាត់ដោះស្រាយចឹង ម៉ាផ្នែកៗ ។

ឈុនលី ៖ ចុះអ៊ំដឹងទេ តាផុនតូចនឹង ដែលគាត់នៅរស់នឹង គាត់ខាងអីគេ?

នាម ៖ អានឹងវា ដល់អស់តាផុនធំនឹងទៅ គាត់អ្នកបញ្ជាទ័ព ។

ឈុនលី ៖ អត់ដឹងត្រកូលដែរ?

នាម ៖ បាទ!

ឈុនលី ៖ ហើយនៅខាងម៉ាឡៃនឹង?

នាម ៖ បាទ!

ឈុនលី ៖ បញ្ជាទ័ពទាំងអស់ខាងតំបន់ម៉ាឡៃនឹង?

នាម ៖ បាទ! តំបន់ម៉ាឡៃនឹង គាត់២នាក់នឹងហើយ ។

ឈុនលី ៖ ចុះច្បាំងគ្នារហូត តំបន់នឹងមានមីន ចាប់ផ្តើមមានមីនពេលណា?

នាម ៖ មីនយើងចាប់ផ្តើមមាន បើតាំងពីនិយាយរួម៧៩ ៨០មានរហូតមីន ។

ឈុនលី ៖ ខាងណាដាក់?

នាម ៖ ព្រំដែននេះវៀតណាមគេដាក់ទៅ គេធ្វើរបងលួសអីចឹងទៅណា ។

ឈុនលី ៖ អានឹងពេលយើងរត់មកនឹងបានមានមីន ៧៩ដល់ពេលយើងរត់មកនឹង?

រិទ្ធ ៖ បារត់មកដែលថាយើងរត់មក យួនដេញ ខ្មែរក្រហមចាប់ដាក់មីនហើយ ។

ឈុនលី ៖ យើងនៅនេះដាក់ការពារ?

រិទ្ធ ៖ ហ្នឹងហើយយើងដាក់ ដល់កន្លែងណាទាហានខាងក្នុងយួនមកមានទីតាំងវាដាក់មីនការពារទីតាំងវាដែរ ដល់ចឹងដាក់មីនទាំងសងខាង ។ យើងក៏ដាក់ ការពារទីតាំងយើង យើងក៏ដាក់ការពារទីតាំងវាដែរ ។

ឈុនលី ៖ ចឹងនៅតែច្បាំងគ្នារហូត?

រិទ្ធ ៖ នៅ ចឹងបានថា៩៦បានដាច់ ។

ឈុនលី ៖ អ៊ំមានបានជម្លៀសទៅថៃអីនឹងគេ ទៅទឹកដីថៃ?

នាម ៖ ទៅឆ្នាំ៨៤ ១៩៨៤ ដែលយើងយួនវ៉ៃបែកព្រំដែនយើងទៅនោះ ។

រិទ្ធ ៖ ៨៥ ។

នាម ៖ ១៩៨៥ យើងទៅនៅចូលដីថៃ ។

ឈុនលី ៖ នៅដីថៃ?

នាម ៖ បាទ!

ឈុនលី ៖ អានឹងនៅជំរំអីគេ?

នាម ៖ គេហៅជំរំ៨៥ ។

ឈុនលី ៖ ជំរំ៨៥ឈ្មោះវាពីដើមមកចឹង?

នាម ៖ ទេអានឹង ។

រិទ្ធ ៖ ដែលយើងឆ្នាំ៨៥បែកពីនេះទៅចូលនៅនឹងគេដាក់ឈ្មោះជំរំចឹងបណ្ដោយ ជំរំ៨៥ ។

ឈុនលី ៖ មកពីយើងរត់ទៅឆ្នាំ៨៥ ?

រិទ្ធ ៖ ហ្នឹងរត់៨៥ ។

ឈុនលី ៖ ពេលនឹងដូចជាអ្នកណាខ្លះដែលរត់ទៅទឹកដីថៃ?

នាម ៖ ទេ! ទៅទាំងអស់ ។

ឈុនលី ៖ ទាំងអស់គ្នា ដីនឹងមិនទំនេរ?

នាម ៖ បាទ! ទំនេរៗនឹងឯង ដីទំនេរណា ចឹងទាំងទ័ពទាំងប្រជាពលរដ្ឋអីនឹង គឺទៅនៅជំរំ៨៥ទាំងអស់ ដីនេះមានព្រៃឈើ ហើយនឹងវៀតណាមគេនៅឆ្កែលជុំវិញចឹង ។

រិទ្ធ ៖ ប៉ុនមិនមែនថាទៅទាំងអស់ទេ ទាហាននៅការពារតាមមាត់អូរ ទៅតែកម្លាំងប្រជាជនដែលធំត្រង់នឹង ទៅបោះទីតាំងហើយមកវិញ ។

ឈុនលី ៖ ទៅហើយមកវិញទៀត?

នាម ៖ បាទ! មកវ៉ៃ ។

ឈុនលី ៖ ចេញចូលរហូត?

នាម ៖ បាទ! ជួនកាលកងចុះមក កងពូខាងនេះឡើង ពូចុះមកខ្ញុំឡើងទៅដូរគ្នាវ៉ៃ ។

ឈុនលី ៖ ចឹងអ៊ំទៅជាមួយពូដែរ?

នាម ៖ ទេ! គាត់នៅខាងវរសេនាធំ ។

រិទ្ធ : យូនមកយើងនៅការពារព្រំដែនចេះ ខ្មែរក្រហមទៅពីដីថៃមកឆ្លងចេះទៅនៅក្នុង វៃពីក្រោយមកវិញមិនចេះ អត់ទល់មុខ ។ និយាយរួមថា បើវៃគ្នាវៃរហូតតាំងពី៧៩រហូតដូចខ្ញុំប្រាប់ចឹង៩៦ ។ ចាប់ពី៧៩មកវៃគ្នារហូត ។

នាម : ៩៦យើងចរចាគ្នា ។

ឈុនលី : អ្នកណាគេអ្នកដឹកនាំចរចាគ្នា?

នាម : អឺ! អ្នកដឹកនាំចរចា វាមានអ្នកណាមានគំនិតគាៗទាំងប៉ុន្មាននាក់នឹង?

ឈុនលី : គាណាខ្លះទៅ?

នាម : នាងកត់ហើយគាមិញ មានតាំងពីដឹង ដុន មានតាំងពីសុខ ភាពមានតាំងពីអីខ្សែគាត់ ។

រិទ្ធ : និយាយរួមយើងចង់និយាយថានៅក្នុងម៉ាឡៃយើងនឹង មានគាត់ ។

នាម : មានគាត់ យើងនិយាយចឹងចុះ មានម្នាក់ ។

ឈុនលី : គាដុន ដឹង ដុន?

រិទ្ធ : បាទ!

ឈុនលី : ដឹត ដុនៗ គាត់គាដុនតូចនឹង?

នាម : ដឹងៗ ។

ឈុនលី : ចុះអ៊ំអត់យល់កន្លែងមួយថា មកចឹងមានអ្នកគ្រប់គ្រងផ្សេង មានទ័ពផ្សេង?

នាម : ថាអត់មានប្រជាជនទេ កាលដែលមកមុនដំបូងនឹង ។

ឈុនលី : ចឹងបានន័យថាប្រជាជនដែលរត់មកជាមួយនឹងចូលធ្វើទ័ពធ្វើអីអស់ហើយ លែងជាប្រជាជនធម្មតា?

នាម : បាទ! គេដូចខ្ញុំរកដូចជា ។

រិទ្ធ : ដូចគាត់ថាសុទ្ធតែកងចល័ត សុទ្ធអត់ទាន់មានប្ដីមានប្រពន្ធទេ ហើយកម្មករមកពីភ្នំពេញសុទ្ធនៅលីវ មកចូលទ័ពចឹងម៉ង ។

ឈុនលី : ចឹងស្រីៗខានដឹកជញ្ជូន?

នាម : បាទ! ដឹកជញ្ជូន ។

ឈុនលី : គេមានអគ្គភាពរបស់គេ?

នាម : មានអគ្គភាព មានគេក្ដោបក្ដាប់កងតូច ពួកក្រុមអីដូចគ្នាទ័ពចឹង ។

ឈុនលី : បើគិតទៅអ៊ំដឹងឬស្គាល់អ្នកថ្នាក់លើច្រើនទេ?

នាម : ទេ! រឿងថ្នាក់លើយើងស្គាល់ត្រឹមកំរិតថាអ្នកណាបញ្ជាយើងតែប៉ុននឹងឧទាហរណ៍ថាមេបញ្ជាការ យើងដឹងត្រឹមប៉ុននឹង បើអ្នកធំៗទៀតយើងមិនដឹងទេ ដឹងគាត់នៅណា ។

ឈុនលី ៖ ហើយមេបញ្ជាលោកភាពនឹង?

នាម ៖ លោកភាព លោកផុននឹង គាត់ទៅប្រជុំណាណែ យើងម៉េចដឹង ។

ឈុនលី ៖ ចុះដូចមេក្រុម ឬមេកងដែលអ៊ំក្តាប់ផ្ទាល់ ថ្នាក់លើមក?

នាម ៖ អានឹងវាដូចថាអាពេលគេត្រូវការ ឧទាហរណ៍ថាខ្ញុំមេកងទៅប្រជុំនៅកន្លែងតា២នាក់នឹង ហើយដឹកនាំផ្នែកបច្ចេកទេស នយោបាយមក ហៅមេក្រុមមកប្រជុំៗហើយមេក្រុមនឹងទៅផ្សព្វផ្សាយដល់គេហៅពលទោល កូនទាហានរបស់ខ្លួនចាប់ផ្តើមដំណើរវិវរបៀបម៉េចអីរបៀបម៉េចទេ អានឹងបច្ចេកទេសគេខាងវ៉ៃ ។ ប៉ុននឹងឯង វាអត់មានផ្នែករៀនដូចនយោបាយអីអានេះគេរៀនពីបច្ចេកទេសវ៉ៃ ព្រោះទាហានរៀនបច្ចេកទេសវ៉ៃៗរបៀបម៉េច ។ វ៉ៃជាសង្គ្រាមឈ្លប វ៉ៃដូចជាដាក់គ្នាដូចខ្សែ ឬក៏វ៉ៃជាទ្រង់ទ្រាយធំអានឹងវាចឹង ។

ឈុនលី ៖ ចុះអ៊ំមានប្រធានកងអីគេដែរ?

នាម ៖ ទេ! ខ្ញុំគ្មានប្រធានកងទេ ពលទ្រេដាំបាយឲ្យគេហូបនឹង ។

ឈុនលី ៖ យើងទ័ពធម្មតា?

នាម ៖ បាទ!

ឈុនលី ៖ ហើយចឹងដូចច្បាំងអី ការហូបចុកអីគ្រប់គ្រាន់ទេ?

នាម ៖ បាទ! មានអី មានអីខ្វះ ។

ឈុនលី ៖ មានរបបត្រឹមត្រូវ?

នាម ៖ បាទ! លុយមានទិញ ។

ឈុនលី ៖ កាលនឹងមានលុយទៀត?

នាម ៖ បាទ! យ៉ាប់តែ៧៩ ហូបបរិបូ ។

ឈុនលី ៖ បានមកពីខាងណាវិញរបប?

នាម ៖ របបឧទាហរណ៍ថាខ្ញុំចូលទៅធ្វើការនៅក្នុង ឧទាហរណ៍ថាទៅពីព្រំដែនទៅក្នុងទៅទិញអង្ករពីប្រជាពលរដ្ឋនៅក្នុង ។

ឈុនលី ៖ ធ្វើម៉េចបានលុយចាយ?

នាម ៖ បាទ! លុយខាងថ្នាក់លើគេផ្តល់ឲ្យ ។

ឈុនលី ៖ គេឲ្យលុយទៀត?

នាម ៖ បាទ!

ឈុនលី ៖ ឆ្នាំ៨០បានមានលុយចាយ?

នាម ៖ បាទ!

ឃុនលី ៖ លុយនឹងលុយខ្មែរ លុយថៃ?

នាម ៖ មកជាលុយដុល្លានឹងមក មកដូរលុយថៃ។

ឃុនលី ៖ លុយដុល្លា?

នាម ៖ បាទ! យើងយកទៅដល់ក្នុងនឹងដូរលុយខ្មែរ ទិញខ្មែរវិញ។

ឃុនលី ៖ នៅនេះមូលហេតុអីខ្លះដែលនាំឲ្យមានសមហរណកម្មផ្តាច់ខ្លួនចឹង?

នាម ៖ ទេ! អានឹងវាដល់កូនទាហានយើងវាមិនសូវដឹងកលល្បិចរបស់គេអ្នកធំៗ ចឹងអាខាងលើអ្នកធំៗនឹងគេសុទ្ធតែដឹងកលល្បិចគេបង្កិលម៉េចៗ ខ្ញុំវាមិនសូវដឹងយើងដើរនយោបាយ។

ឃុនលី ៖ អត់ដែលឮដែរ?

នាម ៖ គេគ្រាន់តែឲ្យយើងខទាហរណ៍ថា ខ្ញុំនៅខាងមុខទប់អ្នកមុខកុំឲ្យវុលមក ហើយគេនៅខាងក្រោយនេះគេចរចាគ្នាទៅខាងសម្តេចនាយករដ្ឋមន្ត្រីអីយ៉ាងម៉េច អត់ដឹង។ ចឹងហើយបានដល់ពេលគេចរចាត្រូវរ៉ូវគ្នាទៅ ដល់យើងនោះអត់បាញ់គ្នា ហើយមេយើងក៏ហៅមកវិញមក ជួបជុំគ្នាអីចឹងទៅ។ តែគេខាងនេះមេធំៗ លោកសុខ ភាព ដូចលោក ជឹង ជុនអី គេទាក់ទងទៅខាងរាជរដ្ឋាភិបាលយើងសព្វថ្ងៃនេះ មិនដឹងជាម៉េចគេទាក់ទងគ្នាដេញនួន ជាអី! សុន សេន។

ឃុនលី ៖ តាសុន សេនហ្នឹង?

នាម ៖ ហ្នឹងហើយ។

ឃុនលី ៖ ហេតុអីបានដេញចឹង មានរឿងអី?

នាម ៖ ទេ! ដល់មកសួរខ្ញុំចឹង ខ្ញុំឆ្លើយអត់ត្រូវ ខ្ញុំវាអត់ដឹង។

ឃុនលី ៖ អ៊ំគិតទៅតំបន់នឹង អ្នកដែលធំជាងគេមានលោកសុខ ភាព?

នាម ៖ បាទ!

ឃុនលី ៖ ចុះដូចតាអៀង សារីអីនោះគាត់នៅណា?

នាម ៖ អានឹង តាអៀង សារី គាត់នៅថៃនោះ យើងម៉េចដឹង។

ឃុនលី ៖ ៧៩គាត់រត់មកនៅថៃទេ?

នាម ៖ បាទ!

ឃុនលី ៖ ចឹងគាត់មិនមែនអ្នកដឹកនាំ គ្រប់គ្រងតំបន់នឹងអីទេ?

នាម ៖ ទេ! អានឹងម៉ាចង្កោមគ្នាគេទៀតហើយ គេចែកគ្នាក្តាប់តាមសមរភូមិ បើនិយាយរួមទៅ។

ឃុនលី ៖ ចែកគ្នាជាមួយអ្នកណាខ្លះទៅ ជាមួយតា?

នាម ៖ ហើយចឹងទៅយើងរើសមក ពីណាតាម៉ុក ហើយតា។

ឈុនលី ៖ គាម៉ុកខាងណា?

រិទ្ធ ៖ នៅអន្លង់វែង ។

ឈុនលី ៖ អន្លង់វែង ចុះក្រោយ?

នាម ៖ គាខៀវ សំផន អឺ!តា ។

រិទ្ធ ៖ សុន សេន នេះ នៅគីឡូ១៣ ៣២ ។

ឈុនលី ៖ ៣២ឥឡូវនឹងទៅជាស្រុកអីហើយ?

រិទ្ធ ៖ ស្រុកសំពៅលូន ។

នាម ៖ ស្រុកសំពៅលូន ស្រុកកំរៀង ស្រុកភ្នំព្រឹក ។

ឈុនលី ៖ នៅវៃគ្នានឹងគេហៅម៉ាឡៃ?

នាម ៖ បាទ! តំបន់សមរភូមិភ្នំម៉ាឡៃ ។

ឈុនលី ៖ សមរភូមិភ្នំម៉ាឡៃ?

នាម ៖ បាទ! ប៉ុនបើចុះទៅវៃក្នុងគេដាក់សមរភូមិស៊ីសាផុន ខាង៣២ទេ ស៊ីសាផុនទទេ ។

ឈុនលី ៖ សមរភូមិស៊ីសាផុន?

នាម ៖ បាទ!

ឈុនលី ៖ អានឹងតំណាងឲ្យខាងម៉ាឡៃ?

នាម ៖ ហ្នឹង សមរភូមិស៊ីសាផុនខាងជើងគឺខាង ពួកតាអីៗដែលថាខ្វាក់ភ្នែកតាសារឿន ភ្នំឆ័ត្រ ។

ឈុនលី ៖ តាសារឿង ឈ្មោះអីសារឿន?

នាម ៖ អត់ដែលដឹង ប៉ុនឮថាខ្វាក់ភ្នែក ។

ឈុនលី ៖ ឥឡូវគាត់រស់នៅទេ?

នាម ៖ មិនដឹងៗរស់នៅខាងណា មុននៅនឹង ។

រិទ្ធ ៖ មកប៉ែកខាងជើងដូចមិនសូវ ប៉ុននៅនឹងអាចសព្វថ្ងៃនៅនឹង ។

នាម ៖ តាវើយ ពួកតាវើយតាអីនេះ ។

ឈុនលី ៖ ស៊ីសាផុននឹង បើគិតទៅមុំខ្វាងរាប់នឹង កន្លែងសមរភូមិស៊ីសាផុន?

នាម ៖ ទេ! ចាប់ពីរហូត ។

ឈុនលី ៖ ចុះកាលនឹងអ៊ំមានគ្រួសារនៅ កាលពេលណាបានអ៊ំមានគ្រួសារ?

នាម ៖ ខ្ញុំមានគ្រួសារតាំងពីឆ្នាំក្មេចទៅទៀត កូនខ្ញុំអាបងនេះកើតឆ្នាំ៨៣ ហើយខ្ញុំបានប្រពន្ធ៨២ ។

ឈុនលី ៖ ៨២?

នាម ៖ បាទ!

ឈុនលី ៖ ចុះដល់ពេលអ៊ំមានគ្រួសារចឹង គេឲ្យអ៊ំនៅជារបៀបជាកងដូចអ៊ំនិយាយថានៅកំលោះ?

នាម ៖ បាទ! នៅចឹង នៅទៅជាមួយដែលទៅពលទោនឹង ម៉ាចង្កោមគ្នា ។

ឈុនលី ៖ ចុះគ្រួសាររបស់អ៊ំ គាត់ធ្វើអី?

នាម ៖ គ្រួសារខ្ញុំនឹង ឧទាហរណ៍ថាយើងមិននៅជាក្រុមចឹង ផ្ទះយើងធ្វើមួយ ប៉ុននៅក្នុងក្រុមនឹងដែរ ហើយគ្រួសារនឹងនៅក្រោយនឹងគ្មានធ្វើអី នៅតាមមាត់អូរនឹង ដាំស្ពៃ ដាំឆៃថាវ ចិញ្ចឹមមាន់ ទៅបើកអន្លុរបើកអីយកមកហូបខ្លួនឯងទៅ មានប៉ុននឹង ។

ឈុនលី ៖ ចឹងផ្ទះអ៊ំនៅណាទៅ ពេលចូល៧៩ហ្នឹង?

នាម ៖ អូ! ខ្ញុំនៅ៧៩ៗខ្ញុំចូលមកគឺឆ្ងាយនៅនោះម៉ង ។

ឈុនលី ៖ នៅណា?

នាម ៖ នៅភូមិដូង ។

ឈុនលី ៖ ភូមិដូង?

នាម ៖ ដែលថៃគេហៅនងពឺ ឆ្ងាយអានឹងអត់មានរឿងអីទេទៅនឹងម៉ង ។

ឈុនលី ៖ ចឹងដូចអ៊ំថាគេបង្កើតឈ្លបអីចឹង គេបង្កើតនៅភូមិដូង?

នាម ៖ ហ្នឹងហើយ គេបង្កើតហើយបានយើងចុះទៅវៃ ។

ឈុនលី ៖ ចុះមកនៅនេះពេលណា?

នាម ៖ មកនៅនេះ និយាយរួមទៅ បើយើងចុះមកនៅឆ្នាំ៩០គត់ឆ្នាំ១៩៩០ ។

ឈុនលី ៖ ហេតុអីបានដកមកនេះវិញ?

នាម ៖ ហើយចុះយើងរំដោះព្រំដែនបាន យើងចុះមកពីជំរំខ-៨៥ ។

ឈុនលី ៖ ពេលណាចុះមកវិញ?

នាម ៖ ឆ្នាំ៩០គត់ ១៩៩០គត់ ។

ឈុនលី ៖ គ្រួសារអ៊ំកាលនឹងគាត់ធ្វើអី មុនពេលអ៊ំរៀបការនេះ?

នាម ៖ ដឹកជញ្ជូន ។

ឈុនលី ៖ នារីដឹកជញ្ជូន?

នាម ៖ បាទ!

ឈុនលី ៖ មានអង្គភាពគេចឹងទៅ?

នាម ៖ បាទ! មានអង្គភាពគេចឹងទៅ ។

ឈុនលី ៖ ដល់ពេលការហើយឈប់ទៅដឹកជញ្ជូនទៀតហើយ?

នាម ៖ ឈប់ ។

ឈុនលី ៖ កាលនឹង គេការមានច្រើនគូទៀតអត់ ដូចពូមុនអត់?

នាម ៖ ទេ! គេការម៉ាគូៗ មិនដូច៧៥ ឧទាហរណ៍ថាខ្ញុំជាមួយពូចឹងត្រូវរូវគ្នាទៅ ប្រាប់ប្រធានមេទៅឯងមានលុយមានកាក់អីទិញអីៗ ហើយចុះយើងនៅជិតព្រំដែនចឹង យើងអាចទិញថៃបានៗ ទិញមាន់ ទិញទា ឬក៏មាន់ទាខ្លួនឯងស្រាអីទិញយកមកផឹកៗ កាលនោះយុទ្ធជនអត់ចេះផឹកស្រាទេៗ

ឈុនលី ៖ ម៉េចចឹង?

នាម ៖ ចុះវាអត់ចេះ វាចេះទឹកក្រូច ទឹកសារ៉ូណានោះ ដល់មកសម័យផ្តាច់ខ្លួននេះ យុទ្ធជនអត់បានប៉ះស្រាម៉ាញញឹមៗ

ឈុនលី ៖ អានឹងរបៀបដូចសែន មិនមែនការ?

នាម ៖ ហ្នឹងហើយរបៀបដូចយើងសែនចឹង ឧទាហរណ៍ថា មានម៉ាញ៉ែមានក្មេងការក្មេងអីនឹង ឧទាហរណ៍ថាពូនឹងមេកង ហើយយូនឹងធ្វើឪ នារីនឹងមេកងគេធ្វើម៉ែទៅ គេអង្គុយក្បាលកន្ទេលក្បាលអីនឹងគេសែនហៅខ្មោចដីដូនដីតាណាណៃដែរនឹងៗ ហ្នឹងចឹង បើយើងការទាំងរ៉ូងៗហ្នឹងសម័យ៧៥ ៗ

ឈុនលី ៖ អ៊ំដែលឃើញគេការ?

នាម ៖ ហ៉េ! មិនទៅបៀតគេទេ យើងនៅតូចជាងគេៗ

ឈុនលី ៖ កាលនឹងអាយុប៉ុន្មាន?

នាម ៖ ខ្ញុំកាលនោះនៅអាយុ១៨ ១៩ ៗ

ឈុនលី ៖ អ៊ំដល់ពេលចូលមកខាងថៃឆ្នាំ៩០ យើងនៅភូមិនេះភ្លាម?

នាម ៖ ហ្នឹងៗ

ឈុនលី ៖ ដោយសាររំដោះបានចឹង?

នាម ៖ ហ្នឹងៗ

ឈុនលី ៖ ចុះមកនៅនេះភ្លាមចឹង ថាស្ថានភាពនៅនេះ យ៉ាងណាដែរ អស់ព្រៃ អស់អីឬមួយ?

នាម ៖ អត់ទេ គឺនិយាយរួម ឧទាហរណ៍ថានាងមក គឺនាងវែកម៉ាកន្លែងនៅ ខ្ញុំមកខ្ញុំវែកតពីនាងមកម៉ាកន្លែង ពូមកតពីខ្ញុំម៉ាកន្លែងចឹងណាៗ

ឈុនលី ៖ អត់មាននៅឆ្ងាយពីគ្នា?

នាម ៖ ទេ! អត់នៅឆ្ងាយទេ នៅចឹងឯងៗ

ឈុនលី ៖ ចឹងអ្នកណាចង់បានដីធំធ្វើទៅ?

នាម ៖ អ្នកណាចង់បានដីធំគេកាប់បានច្រើនទៅៗ

ឈុនលី ៖ ចុះឈើធំៗកាប់ធ្វើអី?

នាម ៖ កាប់ធ្វើនេះ ។

ឈុនលី ៖ ធ្វើផ្ទះ?

នាម ៖ បាទ!

ឈុនលី ៖ ហ្នឹងឈើសុទ្ធកាប់?

នាម ៖ បាទ! យើងកាប់ យើងអារទៅ ។

ឈុនលី ៖ កាលនឹងអស់មីននៅ?

នាម ៖ មានមីន មិនអត់ទេ ។

ឈុនលី ៖ តំបន់នឹងមានផ្ទុះ កាលនៅដំបូង?

នាម ៖ ទេ! តាមនេះ យើងសន្និដ្ឋានថាអត់ ក៏យើងសន្និដ្ឋានមិនបាន សន្និដ្ឋានថាមានក៏យើងសន្និដ្ឋានមិនបាន ព្រោះអាតំបន់ តែកាលណាប្រយុទ្ធគ្នា មិនដឹងជាអ្នកណាដាក់ នាងដាក់ក៏មិនដឹង ខ្ញុំដាក់ក៏មិនដឹង ពួខាងនោះដាក់ក៏មិនដឹង បើយើងវែកទៅវាអត់មានមីន សន្មតថាដីនឹងអត់មីនៗ ដល់យើងរុករានទៅក្រោយប៉ះមីនចឹង យើងប៉ះមីន យើងដឹងថាដីនឹងមានមីនៗ ដល់ឆ្នាំមានពួកស៊ីម៉ាក់ចុះមកចឹង ។

ឈុនលី ៖ ឆ្នាំណា?

នាម ៖ ឆ្នាំណាទេ ខ្ញុំភ្លេចទៅទៀតហើយ ឆ្នាំពួកស៊ីម៉ាក់ ។

ឈុនលី ៖ ហាឡូ ស៊ីម៉ាក់?

នាម ៖ ទេ!

ឈុនលី ៖ បោះឆ្នោតនៅ ផ្តាច់ខ្លួននៅ?

នាម ៖ ផ្តាច់ហើយ ។

ឈុនលី ៖ ក្រោយនេះ?

នាម ៖ ទើបនឹងដោះដែលនឹង ។

ឈុនលី ៖ អាច២០០០ជាង?

រិទ្ធ ៖ អាចឆ្នាំ២០០០ជាង ២០០១ ២០០២ ។

នាម ៖ បាទ! ប៉ុននឹង ។

ឈុនលី ៖ អ៊ំចុះដូចខាងមាត់អូរ អ៊ំស្គាល់សារតាំងទេ កាលនឹងអាកន្លែងសារតាំង?

នាម ៖ សារតាំងនៅនោះ ប្អូនចង្អុរទៅនេះមិនមែនទេ សារតាំងវានៅភូមិដូងនោះ ។

ឈុនលី ៖ សារតាំងនៅភូមិដូង?

នាម ៖ បាទ! នៅឃុំម៉ាឡៃ ។

ឈុនលី ៖ ហើយអ៊ំស្គាល់ដឹងរឿងថាហេតុអីបានគេធ្វើសារតាំង ធ្វើអីចឹង?

នាម ៖ ទេ! អានឹងតាមដែលយើងរៀនផ្នែកនយោបាយនឹង អាចដឹងថាកន្លែងសារតាំងនឹង គេសម្រាប់ទទួលអគ្គរដ្ឋទូត ។ កាលនោះបើយើងនិយាយទៅកម្ពុជាប្រជាធិបតេយ្យនេះ គេមានទូតគ្រប់ប្រទេស ចឹងហើយគេយកកន្លែងមួយនឹងសម្រាប់ទទួលសារតាំងនឹង។ មានតាំងពីសម្ដេចសីហនុ គាត់មក ។ ឧទាហរណ៍ថា ពួខាងនេះប្រទេសមួយ គាត់ចង់ដាក់ទូតចឹងសម្ដេចយាងមកចឹងទៅ ។

ឈុនលី ៖ ទទួល?

នាម ៖ ហ្នឹង ។

ឈុនលី ៖ ចុះពេលនឹងសម្ដេចសីហនុគាត់ទៅណាវិញ គាត់យាងទៅវិញ?

នាម ៖ គាត់អត់ដែលនៅនេះទេ គាត់តែម៉ាភ្លែតទៅកន្លែងគាត់ មកហើយទៅវិញៗ យើងដឹងម៉េចមិនដឹងគាត់ទៅណា មិនដឹងនៅចិនក៏មិនដឹងនៅឯកូរ៉េក៏មិនដឹងយើងអត់ ។ ប៉ុនថាបើទទួលសារតាំង គាត់ត្រូវមកម៉ាភ្លែតចឹង ទទួលសារតាំងរួចទទួលអគ្គរដ្ឋទូតគេរួច យាងទៅវិញ ។

ឈុនលី ៖ ក្រោយមកអគ្គរដ្ឋទូតគេនៅនឹង?

នាម ៖ នៅនឹងទៅ ។

ឈុនលី ៖ នៅកន្លែងសារតាំងនឹង?

នាម ៖ ហ្នឹងហើយ ។

រិទ្ធ ៖ ដាក់ដូចគេទទួលស្គាល់ចឹងណារដ្ឋកម្ពុជាប្រជាធិបតេយ្យគេទៅ គ្មាននៅ អត់មានកន្លែងស្នាក់នៅទេ មានតែកន្លែងទាហាននឹងម៉ង បើថាដូចចឹងៗមកពីក្រៅគ្មានកន្លែងស្នាក់នៅ ។

នាម ៖ អានេះរបៀបដូចបេះទេក្អួយ របៀបថាម៉ាក្រវល់នេះគេហៅមន្ទីរក្នុង ។

ឈុនលី ៖ អានឹងមានអីគេខ្លះមន្ទីរក្នុង?

នាម ៖ បើនិយាយរួមទៅម៉ាចង្កោមសារតាំងនឹង ។

ឈុនលី ៖ ហើយសម្រាប់តែខាងទូតអីចឹងទេ?

នាម ៖ សម្រាប់គេទំនាក់ទំនងអ្នកធំៗ មិនដឹងគេអ្នកធំប៉ុនណា បើយើងនៅតែក្នុងព្រៃនេះ យើងដើរទៅពីនេះទៅនោះម៉ាថ្ងៃពីស្រុកមិញ បើស្រឡាញ់បេះតែម៉ាភ្លែតទេ ដល់ ។

ឈុនលី ៖ នេះគេហៅភូមិអីគេទៅ?

នាម ៖ ភូមិអូរស្រឡៅ ។

ឈុនលី ៖ ភូមិអូរស្រឡៅ ឃុំអូរស្រឡៅដែរ?

នាម ៖ បាទ!

ឈុនលី ៖ អ៊ំថាពេលយើងត្រឡប់មកវិញចឹង យើងរស់យើងចាយលុយរកស៊ីខ្លួនឯងទៀត?

នាម ៖ យើងត្រឡប់ពីច្បាំងមក ។

ឈុនលី ៖ ពេលយើងត្រឡប់មកពីថៃ?

នាម ៖ បាទ! ត្រឡប់ពីថៃយើងរកស៊ីទៅ ។

ឈុនលី ៖ រកស៊ីខ្លួនឯង?

នាម ៖ បាទ!

ឈុនលី ៖ ចុះមានបើករបបឲ្យទៀតអត់?

នាម ៖ គេមិនទាន់ផ្តាច់យើងទេ ពេលនឹងគេនៅតែបើកអង្ករ ត្រីខ ខ្ទាញ់ ខោ អាវ សំលៀកបំពាក់របូត ហើយយើងចេះរកទៅដែរផ្សំទៅលក់ថៃ ។

ឈុនលី ៖ ចុះ៩០នឹងនៅច្បាំងទៀតអត់ ពេលយើងមកហើយចឹង មានច្បាំងអីទៀតអត់?

នាម ៖ ច្បាំង ថាច្បាំងទៅរហូតដល់ប៉ុន្មាន ។

ឈុនលី ៖ ទៅច្បាំងដល់ណា?

នាម ៖ បាទ! ទៅក្នុង ។

ឈុនលី ៖ ចេះដេញចូលក្នុងតិចម្តងៗ?

នាម ៖ បាទ! ដេញគ្នាទៅវៃគ្នាទៅ ។

រិទ្ធ ៖ វាការពិតសមរភូមិនៅតែក្នុងម៉ាជួរសំរោងអីនឹង ។

នាម ៖ សាលាក្រហម ទឹកថ្លា ។

ឈុនលី ៖ ចឹងយើងដេញទៅយើងចេះរត់ចូល?

រិទ្ធ ៖ ការពិតមិនមែនទេ គេហៅថាយើងសមរភូមិ យើងទៅដល់នឹងចឹង យើង......ចូលធ្វើការក្នុងភូមិៗប្រជាពលរដ្ឋនឹង ចូលទៅធ្វើការចូលទៅវៃផ្ទាល់ក្នុងភូមិនឹងកាលនឹងក៏យើងនៅវៃដែរ ។

ឈុនលី ៖ ទៅវៃដល់ក្នុងភូមិទៀត?

នាម ៖ បាទ!

រិទ្ធ ៖ កន្លែងណាទាហាននៅ កន្លែងយួននៅយើងទៅយួននៅយើងវៃនៅកន្លែងនឹង ។

ឈុនលី ៖ ដល់យើងវៃបានហើយ?

រិទ្ធ ៖ វៃបែកទៅ យើងគ្រាន់វៃហើយមិនកាន់មិនឈរជើង យើងត្រឡប់មកកន្លែងយើង វិញ ។

ឈុនលី ៖ ចុះលើកក្រោយបើគេចូលមកដល់កន្លែងនឹងវិញ?

រិទ្ធ ៖ ចូលវិញឲ្យគេនៅទៀតទៅ ថ្ងៃក្រោយយើងទៅវ៉ៃទៀត ។

ឈុនលី ៖ ចឹងបានន័យថាយើងមិនមែនយើងវ៉ៃយកទីតាំងទេ?

រិទ្ធ ៖ អត់ ។

នាម ៖ ឈ្លបម៉េចគេហៅឈ្លប ។

រិទ្ធ ៖ មិនសូវវ៉ៃដូចឆរដើងបាន ។

នាម ៖ ហ្នឹង រៀងឈ្លបវ៉ៃហើយវ៉ៃទៀតៗ វ៉ៃពង្រីកពង្រិលកម្លាំង យើងក៏ស្លាប់ មានគេក៏ស្លាប់ ពេលដែលវ៉ៃម្ដងៗ ប៉ុនដួនកាលទៅយើងទៅយើងជោគជ័យទៅ អត់មានស្លាប់ ។

ឈុនលី ៖ តែយើងទៅជាមួយទ័ព?

នាម ៖ បាទ! ទៅជាអង្គភាពចឹងម៉ង ឧទាហរណ៍ថាអង្គភាពប៉ុន្មាន ២៨ ២៧ ២៦អីទៅវ៉ៃម៉ាទីតាំងនឹងទៅ ។

ឈុនលី ៖ មានអង្គភាព១០៦?

នាម ៖ វរសេនាតូចអានឹង ។

រិទ្ធ ៖ វរសេនាតូច២៦ ២៧ ២៨ ។

ឈុនលី ៖ ចុះ១០៦ ១០៧ ១០៩មានទេ?

នាម ៖ មាន ក្រោយមកមានដល់១០៩ ។

ឈុនលី ៖ ពេលណាបានមាន?

នាម ៖ អានឹងយើងរៀបបណ្ដើរៗ ។

ឈុនលី ៖ ចុះអ៊ីថាឆ្នាំ៨០ដែលគេបានខោអាវឲ្យចឹង កាលនឹងខោអាវយើងដូចទ័ព ចឹងបានយើងទ័ពដែរ?

នាម ៖ បាទ!

ឈុនលី ៖ ចាប់ផ្ដើមចូលទ័ព?

នាម ៖ បាទ! ទ័ព ប៉ុននៅប្រើវិធីសាស្ត្រវ៉ៃឈ្លបដដែល អត់ឲ្យវ៉ៃជាដុំកំភួនទេ ។

ឈុនលី ៖ ទាំងអស់គ្នាត្រូវវ៉ៃបែបឈ្លប?

នាម ៖ ទាំងអស់ ហ្នឹងហើយ ទីតាំងណាដែលយើងដាច់ស្រយាលពីភូមិ ឧទាហរណ៍ថាដាច់ស្រយាលមកនៅកណ្ដាលវាលយកការណ៍ឲ្យច្បាស់ហើយ យកកម្លាំងធំវ៉ៃ....បន្ទាយនឹងកំទេចចោលនឹងកំទេចហើយ យើងអត់នៅនឹងទេ ដកចេញ យកសម្ភារៈដូចជាកាំភ្លើងដូចជាអីហើយ ។

ឈុនលី ៖ គ្រាប់?

នាម ៖ បាទ! អត់មានយកអីទេ យកតែកាំភ្លើង ហើយផុតពីនោះប្រជាជនមកយកៗទៅប្រជាជនខាងក្នុងនឹង ។

ឈុនលី ៖ ហើយចុះអ៊ំស្គាល់ពូឆាប់ៗ គាត់ដូចកាន់ខាងកងដឹកជញ្ជូន?

រិទ្ធ ៖ ឆាប ។

ឈុនលី ៖ ឆាប ហើយឆាប់?

រិទ្ធ ៖ តាឆាប ។

ឈុនលី ៖ នៅម៉ាឡៃ?

រិទ្ធ ៖ ១០៦ ។

នាម ៖ អត់ដែលស្គាល់ទេ តាឆាបនោះ ។

រិទ្ធ ៖ មានឆាប ។

ឈុនលី ៖ កែ ឆាប់?

នាម ៖ អានឹងដល់ទៅទាក់ទងខាងឃុំម៉ាឡៃ ។

ឈុនលី ៖ ខ្ញុំជួបគាត់ហើយ ប៉ុន្តែគាត់កាន់កងដឹកជញ្ជូន បន្ទាប់មកគាត់កាន់ខាងអង្គភាព១០៦ ។

នាម ៖ អូ! អានឹងវាមានចេះ តាឆាបៗ ។

ឈុនលី ៖ កាលនឹងអ៊ំស្គាល់គាត់ដែរ?

នាម ៖ កាលនោះវាចេះ វាមានច្រើនផ្នែកណាស់ តាឆាបនេះវាមានប្រជាពលរដ្ឋដែលគាត់មកពីក្នុងខ្លះៗ ចឹងគេឲ្យតាឆាបនេះទទួលខុសត្រូវតាៗ មីងៗអីនឹងណា ។ ដល់ពេលដឹកជញ្ជូន គាត់ប្រមូលតាៗដឹកជញ្ជូនមក អត់មានស្រីទេ សុទ្ធតែប្រុសម៉ងដឹកជញ្ជូនម្តង ហើយស្រីៗក៏មានដែរក្នុងនឹងគេរួមដំណើរជាមួយតាចាស់ៗនឹងដែរ កងវរៈគេផ្សេងពីគ្នាចឹងទៅ អានឹងវាចឹងគេហៅតាៗ វរៈបែកបន្ទាយណា តាៗនឹងគាត់ទៅរំលាយបន្ទាយនឹងហើយ ។ គាត់ទៅរើបអូសយកអីៗម៉ង ។

ឈុនលី ៖ ខ្ញុំដូចឮថា ដូចជាខួងឆ្នាំ៩០ជាងដែរ ឮថាតាសុន សេន គាត់ចង់បង្កើតជាសហករណ៍ដែលប្រមូលទ្រព្យសម្បត្តិឯកជន ប្រមូលឡាន ប្រមូលអាត្រាក់?

នាម ៖ អានឹងវាមានចឹងមែន ។

ឈុនលី ៖ អានឹងម៉េចខ្លះទៅ?

នាម ៖ អានឹងរបស់ដែលយើងរកបានឯកជនរបស់យើង សុន សេន នឹងគេត្រូវប្រមូលទាំងពីរទេះគោ ឡាន ត្រាក់ទ័រ យកទៅដាក់រួម ។ ចឹងហើយបានមានព្រឹត្តិការណ៍៩៦ ។

ឈុនលី ៖ ផ្តាច់ខ្លួន?

នាម ៖ បាទ!

ឈុនលី ៖ ចុះហេតុអីក៏ តាសុន សេន គាត់កាន់ខាងស្អីគេ?

នាម ៖ អគ្គបញ្ជាការទូទាំងប្រទេស ។

ឈុនលី ៖ ពេល៧៩ហ្នឹង?

នាម ៖ ហ្នឹង ។

ឈុនលី ៖ ហើយដល់តាំងពីជំនាន់ពាន់ឆ្នាំមក?

នាម ៖ ហ៎! មិនដឹងទេ ខ្ញុំមិនដឹងទេអានឹង បើ ។

រិទ្ធ ៖ និយាយចាប់ពីយើងរត់យួនមក ។

នាម ៖ បាទ! ចាប់តែពីយើងរត់មក គឺគេនឹងហើយ ។

ឈុនលី ៖ ចុះក្រែងគាត់កាន់នៅតំបន់ផ្សេង ហេតុអីបានគាត់ចង់ប្រមូល?

នាម ៖ អត់ទេ អានឹងវាអគ្គបញ្ជាការទូទាំងប្រទេស ប្រមូលគ្រប់សមរភូមិ គ្រប់មុខសញ្ញា ។

រិទ្ធ ៖ វាឧទាហរណ៍ថាផ្នែកទាហាន គាត់មេទូទាំងប្រទេសខ្មែរក្រហម គាត់អ្នកក្តាប់ខាងទាហាន

នាម ៖ ដូចលោកទៀ បាញ់ រាល់ថ្ងៃនឹង ។

ឈុនលី ៖ ដូចលោកសុខ ភាព គ្រាន់គេចែកតំបន់ទេ?

នាម ៖ អឺ! ហ្នឹងហើយគេចែកជាតំបន់ទេ តំបន់សមរភូមិ ។

ឈុនលី ៖ ចុះពេលនឹង បានន័យថាយើងនៅនេះយើងមិនពេញចិត្តបានមាន នាំឲ្យមានហេតុការណ៍នឹង កើតឡើង?

នាម ៖ បាទ! ធម្មតាទេនាង ធ្លាប់តែមានឡាន ជិះឡានទៅលេងភូមិដូង ឬក៏ទៅលេងយាយអ៊ិតនឹង ហើយគេប្រមូលឡានយើងទៅដាក់រួម ។ ហើយនាងអន្ទុយមើលឡានខ្លួនឯងត្រមក់ៗ ហើយឡានគេបរកាត់ភក់កាត់អីចឹងទៅ ។ ដល់មេៗយើងមេភាព មេដុន គាត់ឈឺក្បាល គាត់ដល់គាត់ឈឺក្បាលគាត់ អានឹងហើយបានវាមានឆ្នាំ១៩៩៦នឹងកើតឡើង ។

ឈុនលី ៖ ម៉េចខ្លះទៅបើគាត់អត់សុខចិត្តនឹង បើគាត់តូចជាងគេ?

នាម ៖ ហ៎! តូចជាងគេ អានឹងស៊ីសងលើកម្លាំង ឧទាហរណ៍ម៉ាកម្លាំងខ្ញុំនេះមានប៉ុន្មានមានពាពាន នាក់ ហើយសុន សេននឹង ។ សុន សេនចឹង?

ឈុនលី ៖ ចា៎! សុន សេន ។

នាម ៖ គាត់មានប៉ុន្មានមកទប់ជាមួយពួកខ្ញុំ ធម្មតាទេតែមេគេក្តាប់ផ្ទាល់ គេពង្រឹងកូនទាហានគេបាន ហើយ ។ ហើយបើថាគេពង្រឹងបានគ្រាប់ក៏មិនខ្វះ កាំភ្លើងមិនខ្វះ ព្រោះគេភ្ជាប់គ្នាជាមួយទៅខាងរដ្ឋកម្ពុជាហើយ ពេលនឹង ។ ចឹងហើយគេដេញ សុន សេននឹងចេញទៅ ។

ឈុនលី ៖ ចឹងបានន័យថាយើងត្រូវគ្នាជាមួយខាងរដ្ឋកម្ពុជាមុន?

នាម ៖ បាទ! អានឹងទាល់តែរកខ្លួនរៀងខ្លួន មុននឹងយើងធ្វើអីមួយ ដូចនាងចឹងថាធ្វើអីមួយពឹងអ្នកណាមួយម្នាក់អីចឹងទៅ ...វ៉ៃខ្ញុំ ។

រិទ្ធ ៖ បេះណាវាមិនមែនម៉ាឡៃៗពឹងពាក់ប៉ៃលិន ។

ឈុនលី ៖ ចុះខាងលោកអ៊ី ឈាន?

នាម ៖ ហ្នឹងហើយ ។

រិទ្ធ ៖ ហ្នឹងហើយ ខាងនេះទាក់ទងខាងនោះ ដូចថាចិត្តខាងនេះខាងនោះវាដូចគ្នា ហើយនៅប្រឡោះកណ្តាលនេះវាចិត្តផ្សេង អានឹងហើយដែលលំបាក ។ ចឹងបានមិនហ៊ានតតាំង ។

នាម ៖ សុន សេននេះ ឧទាហរណ៍ថានៅកណ្តាលនេះម៉ាឡៃ នេះប៉ៃលិន ២នាក់នឹងវាត្រូវគ្នា អានេះហ៊ានកំរើក ។ ហើយបើអានេះមកវ៉ៃអានេះៗ ចឹងបានវាមាន៩៦នឹង ។

រិទ្ធ ៖ ការពិតទៅយើងធ្វើសមាហរណកម្ម កាល៩៦អត់ផ្ទុះអាវុធ ស្រួល ស្ងាត់ ។

ឈុនលី ៖ ម៉េចខ្លះ គេធ្វើម៉េច?

រិទ្ធ ៖ ធ្វើម៉េច ដូចថាខាងនោះ ដល់ខាងនេះប្រមូលកម្លាំងចឹងទៅ ដាច់ខ្លួនចឹងទៅម៉ង ឡានទៅជិះឡាន រថក្រោះ ។

នាម ៖ ទៅចាប់ដៃគ្នា ។

ឈុនលី ៖ ទៅជួបគ្នានៅណាទៅ?

នាម ៖ ជួបគ្នានៅ៣២ កន្លែងអាកន្លែង ។

រិទ្ធ ៖ ដល់ចឹងអាកម្លាំងនឹងអត់ហ៊ានបាញ់ទេ មុនដំបូងគេត្រៀមដែរ ត្រៀមប្រុងវ៉ៃទៅ ដល់ឃើញកម្លាំងយើងខ្លាំងទៅខាងនេះផង ពីក្រោយចឹងក៏ទ័ពនឹងនៅផ្ទះធម្មតា មិនរត់ទៅណាទេ គ្រាន់អត់តតាំងទេ ។ យើងមិនទៅវ៉ៃស្អី បើអត់តតាំង យើងគ្រាន់ទៅៗ ។

នាម ៖ យើងទៅ គេហៅរំលាយរដ្ឋអំណាច ។

រិទ្ធ ៖ ពីខាងត្បូងក៏មក យើងក៏ទៅចាប់គ្នាវាចប់ ។

ឈុនលី ៖ កាលនឹងអ្នកណាតំណាងចាប់ដៃគ្នានឹង លោកសុខ ភាពនឹង?

នាម ៖ មានតា ។

ឈុនលី ៖ ហើយជាមួយ?

នាម ៖ អានឹងអ៊ី ឈានមក ។

ឈុនលី ៖ ហើយជាមួយខាងរដ្ឋកម្ពុជាយើងអ្នកណា?

នាម ៖ អត់ទេ អត់មានមកទេ អត់ឲ្យប្រឡូកប្រឡល់ទេ ។ រដ្ឋកម្ពុជាវាមានត្រឹម ។

រិទ្ធ ៖ អានឹងបេះ គ្រាន់អាចខាងលើៗគេទំនាក់ទំនងគ្នា តែឲ្យកម្លាំងមកអត់មកទេ។

នាម ៖ អត់យកមកទេ អត់ឲ្យមកប្រចូលប្របល់។

ឈុនលី ៖ ចុះពេលដែលសម្ដេចហ៊ុន សែន យាងមក?

នាម ៖ យាងមកអានឹងយើងធ្វើវាបានអស់ហើយ ដូរព្រំដែន វាថាសមាហរណកម្ម។

ឈុនលី ៖ បានគាត់មក?

នាម ៖ បាទ!

ឈុនលី ៖ ចុះកាលនឹងតាអៀង សារីគាត់យល់ព្រមឲ្យចូល?

នាម ៖ ចុះគាត់មានថាអី បើគាត់មិនដឹង មិនដែលសុខ ភាព មិនដែលដឹង ផុន មិនដែល អ៊ី ឈាន អីហ៊ានធ្វើទេ។

ឈុនលី ៖ ចឹងគាត់គ្រប់គ្រងខាងពួកគាត់នឹង?

នាម ៖ ហ្នឹង។

រិទ្ធ ៖ ទូរខាងលើ ចឹងខាងក្រោមសមរភូមិ សុន សេន, អៀង សារី, នួន ជា, ប៉ុល ពត, តាម៉ុកនេះ ចង្កោមខាងលើ តែគាត់នឹងក៏ចែកសមរភូមិគ្នាដែរ។ នៅក្នុងម៉ាខ្សែអៀង សារី បើនៅខាងជើងកន្លែង៣២នេះ សុន សេន នៅខាងមុខនោះតាម៉ុក។

ឈុនលី ៖ ខាងអន្លង់វែង?

រិទ្ធ ៖ បើនៅត្បូងទៀតទៅ នួន ជា។

ឈុនលី ៖ អានឹងអីគេ?

រិទ្ធ ៖ ហ្នឹងទៅសំឡូតអីទៅ។

ឈុនលី ៖ សំឡូត?

រិទ្ធ ៖ សំឡូត កោះកុង។

ឈុនលី ៖ ចុះតាខៀវ សំផន?

នាម ៖ អានឹងគាត់នៅខាងក្រៅប្រទេស នាយករដ្ឋមន្ត្រី។

ឈុនលី ៖ គាត់អត់មានក្ដាប់អីទេ?

រិទ្ធ ៖ គាត់អាចដើរខាងក្រៅ។

ឈុនលី ៖ អ៊ំបើគិតទៅកាលនឹងបើសិនយើងអត់ចូលផ្ដាច់ខ្លួន ប៉ុន្តែយើងត្រូវគ្នាខាងអ៊ី ឈាន ជាមួយនឹង លោកសុខ ភាពនឹងទៅ ម៉េចបានចឹង? ហេតុអីបានគេបង្កើត២នឹងវៃមួយកណ្ដាលនឹងទៅចាំបាច់?

រិទ្ធ ៖ វាចេះមិនមែនតែមួយនឹងណា ខាងជើងក៏នៅខ្មែរក្រហមខាងត្បូងនោះក៏នៅ ត្រូវគ្នាតែ ២នឹងទេ ២នឹងនាំមុខគេហើយ ។

ឈុនលី ៖ ចឹងបានន័យថាក្រោយពីយើងផ្តាច់ខ្លួនមក កន្លែងផ្សេងៗគេផ្តាច់តាមក្រោយ?

នាម ៖ បាទ!

ឈុនលី ៖ ដោយសារតែយើងអស់គ្នាមើលទៅ?

រិទ្ធ ៖ បាទ!

ឈុនលី ៖ បើគិតទៅខាងណាអ្នកក្រោយគេ?

នាម ៖ អ្នកក្រោយគេដើង ។

ឈុនលី ៖ ខាងអី!?

នាម ៖ អន្លង់វែង ។

ឈុនលី ៖ ខាងតាប៉ុលពត?

នាម ៖ អឺ! អានេះវាគ្រាន់តែខ្ញុំនិយាយខាងដើមៗមិញ ៣២ ម៉ាឡៃ ប៉ៃលិន ព្រោះ២នាក់នេះរួមគ្នារំលាយរដ្ឋអំណាចដេញ សុន សេន ពីកន្លែងនឹងចេញទៅឲ្យទំពនឹង គេទៅប្រាប់ថាឯងតស៊ូដល់ណាទៀតប្រយ័ត្នឆាប់អីចេះចុះចាប់ដៃគ្នា ។ យើងរួមគ្នាទាំងអស់នឹងទៅទៀតហើយ ទៅដល់ស្អី សំឡូត កោះកុង ទៅដេញតា នួន ជានោះទៀត ។

ឈុនលី ៖ ចឹងគាត់ទៅណា គាត់រត់ទៅណា?

នាម ៖ គាត់រត់ទៅនៅដើង ទៅនៅអន្លង់វែង ។ ចឹងបានខាងនេះមូលមតិគ្នាហើយអីហើយបានឲ្យខាងនោះគេធ្វើខ្លួនគេទៅ យើងនេះធ្វើបានម៉ាប៉ែកធំហើយ ។

រិទ្ធ ៖ កុំអីមិននេះដោយសារតែសុន សេនគាត់រៀងប្រមូលអីចឹង កុំអីរកវៃគ្នា បើថារៀងប្រមូលអ្នកណាគេចង់៣ឆ្នាំម៉ាសារហើយ ។ ដល់ប្រមូលចង់ធ្វើរួមគេមិនព្រម ។

នាម ៖ ចង់៣ឆ្នាំម៉ាសារទៀត វាទៅអត់រួចទេ ៥ឆ្នាំ ។

ឈុនលី ៖ កាលនឹងបើគិតទៅជំនាន់៣ឆ្នាំអីលំបាកអីគេ?

នាម ៖ អូ! ៣ឆ្នាំ ខាងខ្ញុំ ទាំងប្រពន្ធខ្ញុំវាលំបាកហើយ លំបាកត្រង់ថាយើងហូបអត់សូវគ្រប់ ហើយយើងធ្វើការជួនកាលយប់ ជួបកាលអត់មានពេលសម្រាកណា ប៉ុននឹងទេ ។ ហើយបាយនឹងរបៀបដូចថាគេចំហុយ ម៉ាស្អីឡាំងស៊ីនៗម៉ាឡាំស៊ីនបួននាក់ៗហូបគ្រប់មិនគ្រប់ឆ្អែតមិនឆ្អែតគឺ ។

ឈុនលី ៖ ហូបបាយរហូត?

នាម ៖ បាទ!បាយរហូត អត់មានបបរទេ ។

ឈុនលី ៖ កាលពន្នាំបាយរហូត អត់ដែលបបរទេ?

នាម ៖ អត់ទេខាងកងចល័ត អានេះកងចល័ត ។

ឈុនលី ៖ ចុះដល់ពេលសម័យសង្គ្រាម អ៊ំគិតថាលំបាកៗអីទេ?

នាម ៖ ទេ! សម័យសង្គ្រាមបើគិតទៅដូចជាអត់ពិបាក វាទៅទាំងអស់គ្នាហើយ ។

ឈុនលី ៖ អត់ពិបាកទេ?

នាម ៖ បាទ! វាពិបាកត្រង់តែយើងគេ ។

ឈុនលី ៖ ចុះការហូបចុកអី?

នាម ៖ អត់និយាយរឿងការហូបចុក ថាមិនគ្រប់ទេ ។

រិទ្ធ ៖ ៧៩ហើយពិបាកដែរ ពិបាកត្រង់ហូបចុកអី យើងមកដំបូង ។

ឈុនលី ៖ អាពេលចូលភ្ជាមនឹង?

រិទ្ធ ៖ យើងហូបបបរដែរ ។

ឈុនលី ៖ ប៉ុន្មានខែទៅ?

នាម ៖ អឺ! សឹងមិនដល់ខែផងនឹង កាកបាទគេមកប្រឹបៗ ។

ឈុនលី ៖ កាកបាទខាងណា?

នាម ៖ បាទ!

រិទ្ធ ៖ ខ្មែរក្រហមកាកបាទមកពីក្រៅ គេមកដាក់នៅដីទីតាំងនៅថៃចឹង ឲ្យយើងចូលទៅយក អង្ករ ។

នាម ៖ គ្រាន់ចូលបាននារី ។

រិទ្ធ ៖ ពួកដឹកជញ្ជូន ។

ឈុនលី ៖ ចឹងមានតែពួកដឹកជញ្ជូនអ្នកទៅយករបបយកអី?

នាម ៖ គេកាកបាទគេកាកបាទនឹងដូចគេមកចិញ្ចឹមស្រីៗ ឧទាហរណ៍ថានាងម្នាក់ចឹង ។

រិទ្ធ ៖ គេថាជួយអ្នករងគ្រោះគេឃើញយើងចឹងថាយើងរងគ្រោះហើយ បានចឹងគេជួយ ហើយ ។

នាម ៖ ប៉ុនគេមិនសួរឲ្យឃើញទ័ពប៉ុន្មានទេ គេឲ្យឃើញនារីៗនឹង ។

រិទ្ធ ៖ អង្ករ ខ្ញាញ់ ប៉ុនយើងទាហានវាម៉េចនេះ គេឲ្យនារីទៅយក ។

នាម ៖ វាដូចនាងចឹង គេកំណត់មេ ម្នាក់ឯងចិញ្ចឹមទ័ព៤នាក់ នាងរកកម្មវិធីអីទៅយកអង្ករមកចិញ្ចឹម ទ័ពបាន៤នាក់ម៉ាខែនឹង នាងមកដល់នឹងដូរសំលៀកបំពាក់ខោអាវចេញផ្លូវនោះទៅយកមកទៀត ។

ឈុនលី ៖ ចឹងបានន័យថាខាងកាកបាទនឹង គេអត់ដឹងថាយើងខាងក្នុងមានទាហានមានអីអត់ទេ?

នាម ៖ ហ្នឹងហើយ ទាហានអត់ដឹងទេ គេជួយប្រជាជន ។

ឈុនលី ៖ អ៊ំដូចអ៊ំឆ្ងល់កាត់ច្រើនចឹង ដូចថាពេលយើងផ្លាច់ខ្លួនហើយមានការលំបាកអីអត់?

នាម ៖ មកដល់សព្វថ្ងៃនេះ ។

ឈុនលី ៖ តាំងពីពេលផ្លាច់ខ្លួនភ្លាមៗ?

នាម ៖ ទេ! ដល់យើងផ្លាច់ខ្លួនភ្លាមៗដូចជាមិនសូវជាលំបាកអីទេ ដល់យើងផ្លាច់ខ្លួនៗនឹង ខាងនោះយើងអត់ភ័យគេវ៉ៃយើង ។ យើងបកមកវិញ មកនៅជុំប្រពន្ធកូនទាំងអស់គ្នាចឹង អ្នកណាមានប្រពន្ធនៅជុំគ្នាទៅ ។

ឈុនលី ៖ ហើយយើងរកស៊ីអីចឹង?

នាម ៖ រកស៊ីធម្មតា កាប់ចំការ ។

ឈុនលី ៖ គេផ្លាច់របបនៅ?

នាម ៖ បាទ! ដូចមិនទាន់ផ្លាច់ ។

ឈុនលី ៖ ចុះបន្ទាប់ពីសមាហរណកម្ម អ៊ំមានធ្វើទ័ពទៀតទេ?

នាម ៖ យើងនៅជាទ័ពចឹង ។

ឈុនលី ៖ ចុះដល់ពេលណាបានឈប់?

នាម ៖ ខ្ញុំចេះវា ដល់យើងផ្លាច់ខ្លួនមក គេដកពីអន្តភាពទ័ពមកៗក្តោបក្តាប់គ្រួសារទ័ព ហើយ ។

ឈុនលី ៖ អានឹងមានតួនាទីម៉េច?

នាម ៖ អានឹងតួនាទីដូចមេឃុំចឹងដែរ ។

ឈុនលី ៖ កាលនឹងគេបង្កើតហើយ?

នាម ៖ បាទ! គេបង្កើតហើយ ។

ឈុនលី ៖ គិតទៅគេបង្កើតស្រុកម៉ាឡៃឆ្នាំណាទៅ?

នាម ៖ ដូចឆ្នាំប៉ុន្មានទេ ភ្លេចបាត់ហើយ ដឹងនៅឯកសារណាទៀត ។

ឈុនលី ៖ មានឯកសារ?

នាម ៖ ប្រហែលមិននៅនេះទៀត ។

ឈុនលី ៖ ពូធ្វើខាងជំទប់ទី២?

រិទ្ធ ៖ បាទ!

ឈុនលី ៖ តាំងពីយូរណាស់ហើយ?

រិទ្ធ ៖ តាំងពី២០០០ ២អាណត្តិ ។

ឈុនលី ៖ ផ្ទះពូនៅណាវិញ?

រិទ្ធ ៖ នៅខាងលិចជិតវត្ត ស្វាកសហករណ៍ ។

ឈុនលី ៖ ចឹងកាលពីមុនមកពូធ្វើទ័ពដូចអ៊ីដែរ តែអត់ស្គាល់គ្នាទេ?

រិទ្ធ ៖ ថស្គាល់ ។

ឈុនលី ៖ ស្គាល់ដែរ?

រិទ្ធ ៖ បាទ!

ឈុនលី ៖ ស្រុកកំណើតពូនៅខាងណា?

រិទ្ធ ៖ ខ្ញុំនៅខេត្តតាកែវ ស្រុកទ្រាំង ។

ឈុនលី ៖ ឃុំអីគេ?

រិទ្ធ ៖ ឃុំព្រៃស្លឹក ។

ឈុនលី ៖ ចេញមកពីនឹងឆ្នាំណាទៅ?

រិទ្ធ ៖ ចេញមក៧៩ មុនដំបូងខ្ញុំចេញពីស្រុក ខ្ញុំចេញមកចុង៧៥ ។ ចេញមកនៅភ្នំពេញ ។

ឈុនលី ៖ ដោយសារគេជម្លៀស ឬយ៉ាងម៉េច?

រិទ្ធ ៖ ខ្ញុំចេញមកកាលខ្ញុំនៅនីរសាស្រុកក្នុងសង្គ្រាមណា ដល់រំដោះបែកមកគេរើសយកមកភ្នំពេញធ្វើកម្មករអគ្គីសនី ។

ឈុនលី ៖ នៅណាវិញ?

រិទ្ធ៖ ខ្ញុំមកនៅឡើងមកភ្នំពេញ នៅបានប្រហែល២-៣ខែ ខ្ញុំមកនៅរោងចក្រវារីអគ្គីសនីគិរីរម្យមកនៅនឹង៧៦ ។

ឈុនលី ៖ ពូឈ្មោះអី?

រិទ្ធ ៖ ខ្ញុំឈ្មោះកង រិទ្ធ ។

ឈុនលី ៖ អាយុប៉ុន្មាន?

រិទ្ធ ៖ ៥០ ។

ឈុនលី ៖ នៅភូមិនឹងដែរ?

រិទ្ធ ៖ ភូមិឈើទាល ។

ឈុនលី ៖ ឃុំអូរស្រឡៅ ។ អត់ធ្វើឃុំផង?

រិទ្ធ ៖ អត់ នៅស្មៀន ។

ឈុនលី ៖ ប៉ុន្តែអ៊ីចូល ធ្វើឃុំចឹង ពេលគេបង្កើតស្រុកម៉ាឡៃនឹងម៉ង?

រិទ្ធ ៖ បាទ! និយាយរួមខ្ញុំនៅឃុំមុននឹងទៀត តាំងពីគេរំដោះគ្នា ។

ឈុនលី ៖ ឆ្នាំណាទៅ?

រិទ្ធ ៖ តាំងមុនឆ្នាំ៩៦ ។

ឃុនលី ៖ ពេលនឹងគាត់មកពីថៃវិញឬនៅ?

នាម ៖ មកហើយ ខ្ញុំមកពីថៃខ្ញុំទៅវ៉ៃនៅមុខហើយ បានដល់ក្រោយមកទៀត បានគេដកៗខ្ញុំពីសមរភូមិមកឲ្យ ។ ចុះមីងៗមិននៅតាមនេះគ្រួសារកងទ័ពនៅតាមនេះគេដកឲ្យយើងក្តោបក្តាប់នៅកន្លែងនេះវិញ ។

ឃុនលី ៖ ចឹងយើងកាន់ខាងឃុំទៅ?

នាម ៖ បាទ! កាន់ខាងឃុំ ។

ឃុនលី ៖ តែកាន់ខាងឃុំ ប៉ុន្តែបើត្រូវការទ័ពអីយើងទៅច្បាំងដែរ?

នាម ៖ អត់ទេ ខាងទ័ពគេតំរូវវិញ គេសុំបាយៗចឹងដើរប្រាប់ប្រពន្ធកងទ័ពនឹងដាំបាយទៅ ហើយព្រឹកឡើងយើងដើរប្រមូលមកយកទៅជូនគេដល់សមរភូមិ ហើយយើងមកវិញទៅយើងមានផែនការអីទៀត យើងខទាហរណ៍ធ្វើចំរូង ។ ហើយពូចាស់ៗដែលទៅច្បាំងមិនកើតនឹងឲ្យគាត់ទៅកាប់ឫស្សីធ្វើចំរូងទៅ ។

ឃុនលី ៖ ចំរូងរបៀបម៉េច ប៉ុនៗណា?

នាម ៖ ចំរូងប៉ុនៗនេះ ស្រួចចុងស្រួចគល់ ។

ឃុនលី ៖ ប្រវែងណា?

នាម ៖ ប្រហែលប្រវែងនេះ ។

ឃុនលី ៖ ធ្វើដើម្បីប្រើម៉េច?

នាម ៖ ធ្វើដើម្បីយកទៅចាក់នឹងដី នាងដើរមក ត្រូវមុត គេហៅខ្មាំងដើរមកបុកអាចំរូងនឹង គឺធ្លាយជើងឈឺចុកចាប់នៅនឹងឯង ។

ឃុនលី ៖ ចំរូងនឹងគេមានដាក់អីនៅនឹង?

នាម ៖ បាទ! គេប្រើមាន២ប្រភេទ អាចំរូងមួយអាចំរូងជើងជ័រឆក់ៗ ពិសខ្លាំងណាស់ ។

ឃុនលី ៖ ពិសអីគេ?

នាម ៖ ពិសនឹងគេដាក់តាំងពីក្បាលពស់ ឲ្យតែពិស ។

ឃុនលី ៖ គេយកមកលាយ?

នាម ៖ គេយកមកកាត់បំពង់ឫស្សីយើង ហើយគេដាក់ក្បាលសត្វនឹងហើយនឹងអង់ទ្រីមនឹង ដាក់ផ្សំជុំគ្នា គេយកអាចំរូងនឹងមកញាត់ទៅ ។

ឃុនលី ៖ ហាលវាអត់?

នាម ៖ ហាលវារៀងស្ងួត ទុកចោលត្រាំចោលនឹងក៏បានដែរ ដល់ពេលនេះយើងចង់ជាបាច់ៗហាលវាឲ្យស្ងួត ឬក៏ដាក់ ទាំងបំពង់ផ្ញើទៅមុខ គ្រាន់ប្រាប់គេថាអានៅក្នុងបំពង់នេះចំរូងជ័រឆក់ ។

ឈុនលី ៖ ចុះអត់ជ័រឆក់ម៉េចវិញ?

រិទ្ធ ៖ យើងបោះឆ្នោត៩៨ ក្រុមប្រឹក្សាឃុំបោះឆ្នោតដំបូង៩៨ ។

នាម ៖ ដូចនឹកមិនឃើញ ។

ឈុនលី ៖ ចំរូងនឹងគេប្រើនៅ គេយកទៅដាក់នៅណា?

នាម ៖ យកទៅមុខ ។

ឈុនលី ៖ កន្លែងសមរភូមិនឹង?

នាម ៖ បាទ! ទីតាំងចឹងទៅ យើងដាក់ផ្លែលទីតាំងគេនឹងទៅ ។

ឈុនលី ៖ ហើយដាក់ទៅបានផលច្រើន ចង់និយាយថាមានអ្នកស្លាប់?

នាម ៖ វាអត់មានអ្នកឃ្លាំងមើល តែដាក់ចោលចឹងទៅៗ ប៉ុនបើដាក់វាអាចមានប្រសិទ្ធិភាពខ្លះ ម៉េចបានថាចឹង បើសិនយើងដាក់ផ្លែលហើយ យើងទុកម៉ាដូវ យើងវៃពីខាងនេះ ឲ្យវារត់ទៅៗ ឆ្ងាយចំរូងនឹងហើយ ។

ឈុនលី ៖ ដាក់កប់ដីសល់ប៉ុនណាទៅ មើលអត់ឃើញ?

នាម ៖ ហ្នឹងសល់ប្រវែងៗ នេះពីដីយើងដោតចេះមើលម៉េចឃើញ ។

ឈុនលី ៖ ប្រវែងនឹង មើលអត់ឃើញអី?

នាម ៖ អី! អត់ឃើញទេ ។

ឈុនលី ៖ ដោយសារព្រៃ កប់ស្មៅ?

នាម ៖ មានព្រៃអីកណ្ដាលវាល តែភ័យខ្លាំងនាងរត់ហើយមិនចឹង តែនាងរត់ជាន់ហើយ ចុះកន្លែងផាកក្រោយគេប្រើបៗមិនពើត(សើច) ។

ឈុនលី ៖ អានឹងយើងដាក់របៀបម៉ាខ្សែ?

នាម ៖ អត់ទេ ដាក់ច្រើនខ្សែមិនមែនម៉ាខ្សែទេ ។

ឈុនលី ៖ ដើម្បីគេដុតរួច?

នាម ៖ បាទ! ទេដាក់ច្រើនខ្សែ មិនមែនម៉ាខ្សែទេ ។

ឈុនលី ៖ ដើម្បីគេដុតរួច?

នាម ៖ បាទ! ដាក់ឡើងដូចម្រាមដៃគ្នាពីថ្នល់នឹងមកប៉ុននេះ ទទឹងឡើងប៉ុន្មានថាបើគេកំណត់ថា៣០ គឺ៣០ម៉ែត្រៗ ហើយផ្លែលចឹងទៅ បើមិនផ្លែលទេ គេទុកម៉ាខទាហរណ៍ថាពីនេះមកនេះ ១០០ យើងចាក់ទទឹង៣០ម៉ែត្រឲ្យបាន១០០ម៉ែត្រ ហើយគេវៃពីខាងនេះទៅ ឲ្យវារត់តែពាសនឹងទៅ ។

ឈុនលី ៖ ចឹងបានន័យថាអ្នកគ្រួសារកងទ័ពស្រីៗនឹង គាត់ត្រូវធ្វើចំរូងនឹងច្រើន?

នាម ៖ តា១ ១

ឈុនលី ៖ គេធ្វើច្រើនចឹង?

នាម ៖ បាទ! ទេ គេត្រូវការម៉ាមុខសញ្ញាណា ឧទាហរណ៍ថាខាងនេងអៀន១ គេត្រូវការបំរុងប៉ុន្មាន ៣០០០ ឬ៤០០០ តា១តែ៨-១០នាក់ប៉េះម៉ាប្រុសហើយ ។ កាប់ឫស្សីមក ឫស្សីគេកាប់យកថ្នាំងកណ្តាលចេះមកថាប្រវែងនេះមក ថ្នាំងកណ្តាលសំរួចខាងនេះ១មកប្រគល់ឲ្យគេទៅគេយកទៅបុកនឹងដីដោតចេះមក ។ អានេះគេកម្មវិធីសត្រ្វាមឈ្នប ។

ឈុនលី ៖ ប្រើចំរីង ចំរូង?

នាម ៖ ចំរូង មិនមែនចំរីងទេ ចំរូង ។

ឈុនលី ៖ ចុះអ៊ីដូចថាក្រោយពេលយើងសមាហរណកម្ម ស្រុកយើងស្រួលបួល អ៊ីមានជួបការលំបាកអីទៀតទេ?

នាម ៖ ហ៊ើ! អាដែលយើងនិយាយថាជួបការលំបាកនឹងចេះតែជួបហើយ ។ ដែលយើងកើតជាឃុំមកហើយប្រជាពលរដ្ឋគាត់ជ្រើសតាំងយើងជាឃុំ យើងមានការជួបលំបាកនឹងច្រើនផ្នែក មិនមែនតែម៉ាផ្នែកទេ ។

ឈុនលី ៖ ម៉េច?

នាម ៖ ព្រោះថា យើងវាបានស្រួលហើយ ឧទាហរណ៍ថាច្រើនជួបគ្នាថាម៉េចឯងសុខសប្បាយទេ? ខ្ញុំសុខហើយតែវាមិនទាន់សប្បាយ ។ គេសួរមូលហេតុនឹងមូលហេតុអីបានមិនទាន់សប្បាយ? ប្រជាជនខ្ញុំវាអត់ ។ អានឹងខ្ញុំនិយាយប៉ុននឹង នាងអាចយល់ហើយប៉ុននឹង ហើយដូចសព្វថ្ងៃស្រូវរៀងកើត សណ្តែកសៀងវាស្អុយ ហើយគ្នាយកលុយពីហោជៅគ្នា ខ្លះទៅចងការលុយពីអេស៊ីលីដា ពីធនាគារភូមិ ពីអេអិនខេ ពីស៊ីឡានិធី ចឹងគ្នាយកលុយទៅចោលចំការ ។ ហើយចុះសណ្តែកសៀងវាស្អុយ ហើយគ្នាយកមកលក់ឧទាហរណ៍ថាអាល្អបំផុតបានប៉ុន្មានថា ៣០ចុះម៉ាគីឡូ ឧទាហរណ៍ចុះបើគ្នាប្រូតយកមកលក់៦រៀលយើងគិតទៅ ហើយគ្នាទៅរកលុយណា នេះដល់ពេលខ្ញុំជាមួយមេឃុំ ជាមួយជំទប់ទី១ ទី២នឹង ខ្វល់ខ្វាយសំបើមណាស់ពេលនឹងហើយដែលប្រជាជនយើងថាត្រូវកាត់បន្ថយភាពក្រីក្រ វាកាត់ទៅបន្ថយមែនវាទៅជាក្រច្រើន ។ ចឹងហើយបានថា ធម្មតាដល់ពេលយកលុយឡើងគេ អត់លុយ យើងសង្ឃឹមផលនឹង ប្រជាពលរដ្ឋសង្ឃឹមផលនឹង ដំឡូងក៏ដូចគ្នាដែរ ។ ប្រជាពលរដ្ឋគាត់ខំណាស់ មិនមែនថាមិនខំទេ ត្រូវវាម៉ាឆ្នាំនេះម៉េចម៉ាដល់ស្រូវរបស់គាត់ដាក់បាប់ទៅភ្លៀងមកនៅសល់តែដើមរលួយចុងអស់ ។ ចឹងហើយវាមានណាដែលត្រូវគិត ម៉េឪ ដេកអត់ស្រួល ហូបក៏មិនឆ្ងាញ់ ។ ងាកទៅមើលចេញទៅវាលចេះ ដំឡូងលិចទឹក សណ្តែកសៀងលិចទឹក ដើរមកវិញ

ចូលទៅចំការស្អុយ ដើរមកវិញឃើញស្រូវនឹងខៀវស្រស់អីទៅអានឹងមធ្យមទេ ។ តែសំខាន់ដែលគាត់ធ្វើសំខាន់គឺចំការ ស្រូវនេះជាបន្ទាប់បន្សំរបស់គាត់ទេ ត្រឹម១០០ហិចតាក្នុងម៉ាឃុំ ឬក៏២០០ហិចតាក្នុងម៉ាឃុំ ខ្ញុំថារួចពីចំការរបស់គាត់មក ធ្វើអាស្រូវនឹងសម្រាប់ផ្គត់ផ្គង់ ។ ដល់ឥឡូវនេះកំពុងពេញដីងហើយ ប៉ុន្មានថ្ងៃនេះរាយការណ៍ទៅខាងស្រុកឲ្យគាត់អាច ។

ឈុនលី : ចុះអ៊ំដល់ពេល ដូចពេលអ៊ំត្រឡប់មកវិញហើយចឹង មានបងប្អូនគេមកតាមរកអ៊ំនៅនេះទេ?

នាម : អូ! មកពីស្រុកយើងនឹង ដែលយើងត្រូវគ្នារួចហើយ មានផ្លូវមានអីបងប្អូនចេះមក ។ មុនដីបូងបន្អស់ ខ្ញុំដែលយើងគេហៅថាអ៊ុនតាក់ចូល ខ្ញុំបញ្ជូនប្រពន្ធខ្ញុំ ឲ្យទៅលេងនៅភូមិនឹងកន្លះខែ នាំកូននាំចៅទៅលេងកន្លះ តាំងបងខាងខ្ញុំតាំងបងប្អូនខាងប្រពន្ធនឹង ឲ្យដើរលេងជុំគ្នាទៅ ហើយបានគេដឹងថាខ្ញុំអត់ងាប់ទេ នៅរស់ហ្នឹងហើយ ។

ឈុនលី : ចុះអ៊ំដែលទៅនោះ?

នាម : ខ្ញុំទៅ ដល់ពេលខ្ញុំយើងប្រកាសស្រុកប្រកាសឃុំរួចអស់ហើយ ប្រកាសខេត្តថ្មី ប្រកាសខេត្តបន្ទាយមានជ័យនេះ៩០ប៉ុន្មាន៨៨ ប្រកាសផ្ដាច់ពីខេត្តបាត់ដំបង ។

ឈុនលី : ផ្ដាច់ពីបាត់ដំបង?

នាម : បាទ! យើងទៅខេត្តបន្ទាយមានជ័យទៅយើងឡើងទៅប្រជុំចឹងទៅវាជិតផ្ទះ ។

ឈុនលី : ៨៨ ពេលនឹងអត់ទាន់ចប់សង្គ្រាមណា?

នាម : ទេ! យើង៩៦ ចប់៩៦ ។

ឈុនលី : ចឹង៩៨?

នាម : បាទ! ៩៨ញក៏យើងអត់ទាន់ហ៊ានចូលខាងក្នុងនឹងដែរ គ្រាន់តែឲ្យ ។

ឈុនលី : នៅខ្លាចទៀត?

នាម : ហ៎! និយាយលេងចុះ ។

ឈុនលី : ចឹងក្រែងយើងត្រូវរូវគ្នាហើយ?

នាម : ទេ! វាត្រូវរូវគ្នាពិតទាហាននិងទាហាន វាត្រូវគ្នា ។ ធម្មតាយើងចូលទៅក្នុង យើងចូលទៅឧទាហរណ៍ថាយើងនៅជុំវិញខ្លួនយើងនេះអត់អីទេ យើងចូលទៅក្នុងនោះ អាក្នុងខ្លួនយើងមិនដឹងម៉េចៗ គេចោមស្អប់មួយយ៉ាងម៉េចយើងអត់ដឹង ។

ឈុនលី : ចឹងម៉េចទៅ?

នាម : ទេ! មានម៉េច ខ្ញុំឲ្យប្រពន្ធខ្ញុំទៅៗ ហើយខ្ញុំ ។

ឈុនលី : ហើយដល់ពេលអ៊ំទៅៗពេលណា?

នាម : ដល់ខ្ញុំទៅៗប្រជុំទៅអីទៅ ខ្ញុំទៅលេងផ្ទះខ្ញុំទៅ ។

ឈុនលី ៖ ចឹងគេ?

នាម ៖ ទៅបងប្អូននឹងក៏ដឹងថានៅរស់ទៅ គេមកលេងយើងមក យើងទៅលេងគេទៅ ។

ឈុនលី ៖ គេអត់មានខឹងយើងអីទេ?

នាម ៖ អឺ! មានអីខឹង បុណ្យឲ្យតែបងប្អូនទៅជួបគ្នា ។

ឈុនលី ៖ ដូចថាយើងធ្លាប់នៅខាងនេះ?

នាម ៖ គេគ្រាន់ថាអូ! អាខ្មែរក្រហមមកហើយ បាទ!មកហើយ អញស្មានតែងាប់បាត់ហើយ ។ ងាយងាប់ណា អញឮថាខ្មែរក្រហមស៊ីស្លឹកខ្ទឹង ស្លឹកខ្ទឹងវាត្រូវមែននឹងឯង វាមិនសុខទេវាស៊ីដល់ស្លឹកដុចផង វាត្រូវសាច់ឈ្លូស សាច់ទន្សាយ ប៉ុនបាយអញវាមិនខ្វះស៊ីទេ ឯងមើលតែកូនអញមកមុនដឹងហើយ ។

ឈុនលី ៖ ចុះគេហៅខ្មែរក្រហម អីខឹងអត់?

នាម ៖ ចុះមានអីខឹងនឹងគេ តែយើងវាគេដាក់ងារយើងទៅហើយ យើងមិនដឹងថាម៉េច ព្រោះយើងផ្លាស់ថាកងទ័ពជាតិ គេមិនស្គាល់ទ័ពជាតិអី គេស្គាល់តែខ្មែរក្រហម គេដាក់ឈ្មោះឲ្យយើងស្រេចហើយ ។

ឈុនលី ៖ តាមពិតយើងកងទ័ពជាតិ?

នាម ៖ ហ្នឹងហើយ កងទ័ពជាតិអាយើងស្លៀកពាក់ខោអាវស៊ីម៉ាលីហើយនឹង ។

ឈុនលី ៖ អីស្រុកនេះគេចាប់ផ្ដើមឆ្ការអស់ព្រៃចឹងពេលណា?

នាម ៖ អឺ! មិនដឹងជាពេលណាដែរ ដល់សួរចឹងរកឆ្លើយវាមិនត្រូវ មិនដឹងអស់ពីឆ្នាំប៉ុន្មាន ។

ឈុនលី ៖ អត់ទេ ចង់និយាយថាវាទៅជាភូមិ ទៅជាអីត្រឹមត្រូវ ពីមុននៅមានព្រៃមានអីច្រើនចឹង?

រិទ្ធ ៖ ៩៧ ៩៨នឹងឯង ។

នាម ៖ ហ្នឹងអាចខ្វង់២០០០ ។

ឈុនលី ៖ មានមនុស្សកាន់តែច្រើនមកនៅ?

នាម ៖ បាទ! ខ្ញុំវាមានកូនមានចៅ ចេះតែបែកៗគ្នានឹង ។

ឈុនលី ៖ ចឹងកាលណាយើងមានចំការ យើងកាប់ព្រៃឈើធ្វើផ្ទះធ្វើអី?

នាម ៖ ហ្នឹងហើយ ។

ឈុនលី ៖ ហើយសល់បានលក់អត់?

នាម ៖ លក់ឈើ ។

ឈុនលី ៖ ចាំ! ដូចថាយើងមកនៅ?

នាម ៖ ទេ! ធម្មតាទេ យើងទិញចេញពីស៊ីម៉ង់គេ គ្រាន់យើងរកលក់ខ្លះ ទិញស៊ីម៉ង់គេគ្រាន់យើងរកលក់ខ្លះ ទិញស៊ីម៉ង់ដែកគោលដែកអី សង្ស៊ីអីចឹង ប្តូរគ្រឿងចឹងទៅ។ ចឹងកាប់អានេះយកទៅលក់ ហ្នឹងយកប្រាក់នឹងទិញអានោះមកវិញដដែល ដូចគ្នា។

ឈុនលី ៖ ហើយចឹងអ៊ំឈ្មោះអីគេ?

នាម ៖ ងិន នាម។

ឈុនលី ៖ អាយុប៉ុន្មាន?

នាម ៖ ៥៨ហើយ។

«ចប់»